

# សិទ្ធិមនុស្ស និង ពន្ធនាគារកម្ពុជា៖
# របាយការណ៍ ស្តីពី ស្ថានភាពពន្ធនាគារ
# ឆ្នាំ២០០១

## លីកាដូ

# មាតិការ


បុព្វកថា ---------------------------------------------------- ២
សេចក្តីសង្ខេប ---------------------------------------------------- ៣
ចំនួនពិរុទ្ធជននិងទណ្ឌិត និង ទីកន្លែងចង្អៀត ---------------------------------- ៥
ការឃុំខ្លួនបណ្តោះអាសន្ន ---------------------------------------------- ៩
មរណៈភាពនៅក្នុងពន្ធនាគារ ---------------------------------------១២
អំពើទារុណកម្ម ------------------------------------------------ ១៣
ការបន្ទូរបរិយាកាស និង ការសួរសុខទុក្ខរបស់សមាជិកគ្រួសារ ---------------------១៨
សេចក្តីសន្និដ្ឋាន ---------------------------------------------------២១
អនុសាសន៍ ---------------------------------------------------------២៣
ឯកសារពិគ្រោះ ---------------------------------------------------២៦



ទំនាក់ទំនង : អ្នកស្រី វេជ្ជ. **ពុង ឈីវកេក** ប្រធានអង្គការ លីកាដូ
សរសេរដោយ: ការិយាល័យពេទ្យ និង ការិយាល័យស៊ើបអង្កេត
អាស័យដ្ឋាន : ផ្ទះលេខ១០៣ ផ្លូវ៩៧ សង្កាត់បឹងត្របែក ខណ្ឌចំការមន ភ្នំពេញ
ប្រអប់សំបុត្រ : PO Box 499
ទូរស័ព្ទ : (៨៥៥) ២៣ ៣៦០ ៩៦៥ / ២១១ ៣៩១
ទូរសារ : (៨៥៥) ២៣ ៣៦០ ៩៦៥ / ២១៧ ៦២៦
អ៊ីមែល : licadho@cament.com.kh


ខែកក្កដា ឆ្នាំ២០០២

# សិទ្ធិមនុស្ស និង ពន្ធនាគារកម្ពុជា
# របាយការណ៍ស្ដីពីស្ថានភាពពន្ធនាគារ ឆ្នាំ២០០១

## បុព្វកថា

របាយការណ៍នេះពិពណ៌នាអំពីស្ថានភាពពន្ធនាគារក្នុងឆ្នាំ២០០១ ។ ពត៌មានទាំងឡាយបានមកពីការខិតខំប្រឹងប្រែងរួមរវាងការិយាល័យស៊ើបអង្កេត និងការិយាល័យពេទ្យនៃអង្គការលីកាដូ ពីខែមករាមកដល់ខែធ្នូ ឆ្នាំ២០០១ ដោយផ្អែកលើការសម្ភាសន៍អ្នកជាប់ពន្ធនាគារចំនួន២.៣២៤នាក់ ដែលប្រព្រឹត្តិទៅតាមកាលវិភាគចូលសម្ភាសន៍យ៉ាងទៀងទាត់ជាប្រចាំពេញមួយឆ្នាំ ។ របាយការណ៍នេះបង្ហាញនូវការសិក្សាស្រាវជ្រាវមួយយ៉ាងសំខាន់ទៅលើស្ថានភាពពន្ធនាគារកម្ពុជាបច្ចុប្បន្ន ថ្វីត្បិតបើរបាយការណ៍នេះមិនបានបង្ហាញនូវទិន្ន័យអោយបានល្អិនល្អន់ក៏ដោយ ។

គោលដៅសំខាន់ពីរនៃការស៊ើបអង្កេតមានដូចខាងក្រោមនេះ:

- តើស្ថានភាពទូទៅនៅពន្ធនាគារកម្ពុជាឆ្នាំ២០០១ មានអ្វីខ្លះ ?
- តើបញ្ហាសិទ្ធិមនុស្សសំខាន់ៗដែលត្រូវព្រួយបារម្ភចំពោះអ្នកជាប់ពន្ធនាគារទាំងឡាយមានអ្វីខ្លះ?

អ្នកស្រាវជ្រាវពន្ធនាគារយើងបានធ្វើការទៅលើពន្ធនាគារមួយភាគធំនៅទូទាំងប្រទេស ដោយបានចុះទៅសង្កេតមើលដល់ពន្ធនាគារចំនួន២០ ក្នុងចំណោមពន្ធនាគារទាំង២៥ នៅកម្ពុជា ។ ពន្ធនាគារស៊ីវិលដែលបានសង្កេតមើលទាំងនោះគឺ ពន្ធនាគារខេត្តបន្ទាយមានជ័យ បាត់ដំបង កំពត កណ្តាល កោះកុង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ ប៉ៃលិន មណ្ឌលកែប្រែទី២ (ពន្ធនាគារព្រៃសរ សំរាប់ស្ត្រីនិងកុមារ) មណ្ឌលកែប្រែទី១(ពីមុនហៅថា តេ៣) ព្រៃវែង ពោធិ៍សាត់ សៀមរាប ក្រុងព្រះសីហនុ ស្វាយរៀង និង មណ្ឌលកែប្រែទី៣(ត្រពាំងផ្លុង) ។ ពន្ធនាគារស៊ីវិលដែលបានរៀបរាប់ទាំងនេះ ព្រមទាំងពន្ធនាគារទួលស្លែង (ជាពន្ធនាគារយោធានៅភ្នំពេញ យ៉ាងហោចណាស់ត្រូវបានសង្កេតមើលបីដងក្នុងមួយខែ) គឺជាពន្ធនាគារទាំង២០ដែលយើងបានសង្កេតមើល ។ ពន្ធនាគារចំនួនប្រាំដែលយើងមិនបានធ្វើការសង្កេតមើលនោះ គឺអាស្រ័យដោយលទ្ធភាពនៃកម្មវិធីយើងមានកំរិត ហើយពន្ធនាគារទាំងនោះរួមមាន: ពន្ធនាគារខេត្តព្រះវិហារ ស្ទឹងត្រែង ក្រចេះ មណ្ឌលគីរី និង ពន្ធនាគារខេត្តរតនគីរី ។

អាស្រ័យដោយមានការយឺតយ៉ាវក្នុងការចុះហត្ថលេខាលើលិខិតអនុញ្ញាតថ្មី ដើម្បីអោយបុគ្គលិកស្រាវជ្រាវពន្ធនាគារនៃអង្គការលីកាដូចូលសម្ភាសន៍អ្នកជាប់ពន្ធនាគារ ព្រមទាំងមានការផ្លាស់ប្តូរប្រធាននាយកដ្ឋានពន្ធនាគារថ្មី បណ្តាលអោយអ្នកស្រាវជ្រាវនៃអង្គការលីកាដូយើងជួបប្រទះនូវបញ្ហាដែលមិនអាចចូល

សម្ភាសន៍អ្នកជាប់ពន្ធនាគារបាននៅពន្ធនាគារភ្នំពេញ មណ្ឌលកែប្រែទី៣( ត្រពាំងផ្លុង) ព្រៃវែង សៀមរាប និង ពន្ធនាគារ ស្វាយរៀង ក្នុងកំឡុងពេលខ្លះនៃឆ្នាំ២០០១ នេះ ។

សមាជិកក្រុមការិយាល័យពេទ្យបានចុះពិនិត្យសុខភាព ពិគ្រោះជម្ងឺជាប្រចាំនៅពន្ធនាគារចំនួន១២កន្លែង រួមមានៈ ពន្ធនាគារខេត្តបាត់ដំបង កោះកុង កំពង់ចាម[1] កំពង់ធំ PJ ព្រៃវែង ពោធិ៍សាត់ ក្រុងព្រះសីហនុ ស្វាយរៀង តាកែវ តាខ្មៅ និងពន្ធនាគារទួលស្លែង ។

កម្មវិធីពន្ធនាគារក្នុងការិយាល័យស៊ើបអង្កេតរបស់អង្គការលីកាដូ បានចាប់ផ្តើមចុះស្រាវជ្រាវពន្ធនាគារទូទាំងប្រទេសនៅឆ្នាំ១៩៩៦ ។ របាយការណ៍ពន្ធនាគារចុងក្រោយបង្អស់របស់អង្គការលីកាដូបានរាយការណ៍លំអិតអំពីស្ថានភាពសិទ្ធិមនុស្សក្នុងពន្ធនាគារក្នុងឆ្នាំ១៩៩៩[2] ។ ក្រុមការងារកម្មវិធីពន្ធនាគារធ្វើការដោយធ្វើការរួមគ្នាជាមួយការិយាល័យពេទ្យអង្គការលីកាដូ ដើម្បីវាយតំលៃបញ្ហារំលោភសិទ្ធិមនុស្ស និង សុខុមាលភាពអ្នកទោសទូទៅនៃពន្ធនាគារ ។ ចំពោះពត៌មានបន្ថែមស្តីពីស្ថានភាពសុខភាពក្នុងពន្ធនាគារកម្ពុជា សូមអានរបាយការណ៍[3] លីកាដូឆ្នាំ២០០១ ស្តីពីសុខុមាលភាពអ្នករស់នៅក្នុងពន្ធនាគារ ។

ចំណុចសំខាន់មួយដែលយើងគួរកត់សំគាល់នោះគឺ លីកាដូ បានទទួលបានពត៌មានទាំងនេះពីការសម្ភាសន៍អ្នកទោសក្នុងពន្ធនាគារ ។ វាជាការលំបាកណាស់ ដើម្បីធ្វើអោយមានភាពជាសម្ងាត់នៅពេលសម្ភាសន៍ព្រោះឆ្មាំពន្ធនាគារតែងតែមានវត្តមាននៅក្បែរជានិច្ច ។ ឧបសគ្គក្នុងវិធីសាស្ត្រសម្ភាសន៍នេះ ត្រូវចាត់ទុកជាកត្តាមួយដែលអាចមានផលប៉ះពាល់ដល់របកគំហើញ ដែលវាហួសពីសមត្ថភាពរបស់បុគ្គលិកអង្គការលីកាដូ។

## សេចក្តីសង្ខេប

ស្ថានភាពសិទ្ធិមនុស្សនៅក្នុងពន្ធនាគារកម្ពុជា ត្រូវបានជាន់ឈ្លីដោយបញ្ហាប្រឈមមុខមួយចំនួន អាស្រ័យដោយមួយផ្នែកធំ គឺបណ្តាលមកពីការកើនឡើងយ៉ាងខ្លាំងនូវចំនួនអ្នកជាប់ពន្ធនាគារ ។ ចាប់តាំងពីឆ្នាំ ១៩៩៧កន្លងមកចំនួនអ្នកជាប់ពន្ធនាគារបានកើនឡើងក្នុងកំរិតមួយយ៉ាងខ្ពស់ ។ គ្រាន់តែក្នុងរយៈពេលមួយឆ្នាំ ដោយគិតចាប់ពីឆ្នាំ២000 ដល់២០០១ ចំនួនអ្នកជាប់ពន្ធនាគារបានកើនឡើងរហូតដល់ទៅ ១០% ដែលមាន ចំនួនទណ្ឌិតនិងពិរុទ្ធជន៤៧១នាក់ថែមទៀតលើសពីឆ្នាំកន្លងទៅ ។ ភាគច្រើននៃអ្នកជាប់ពន្ធនាគារទាំងនោះជាបុរស ចំណែកឯស្ត្រីព្រមទាំងកុមារមានត្រឹមតែ (៥.៩% និង ៤.៥%ប៉ុណ្ណោះ) ។ របាយការណ៍នេះបានរៀបរាប់អំពីស្ថានភាពពន្ធនាគារ និង បញ្ហាសិទ្ធិមនុស្សសំខាន់ៗដែលគួរអោយព្រួយបារម្ភនៅក្នុងពន្ធនាគារចំនួន២0 ដែលអ្នកស្រាវជ្រាវ និង ក្រុមការិយាល័យពេទ្យបានសង្កេតមើលជាប្រចាំ ។ អ្នកស្រាវជ្រាវពន្ធនាគារបានសម្ភាសន៍អ្នកជាប់ពន្ធនគារចំនួន ២.៣២៤ នាក់ តាមពេលកំណត់នៅក្នុងឆ្នាំនោះជាប្រចាំ ។

---

[1] *បុគ្គលិកពេទ្យបានចាប់ផ្តើមធ្វើការត្រួតពិនិត្យសុខភាពជាប្រចាំនៅពន្ធនាគារកំពង់ចាមចាប់ពីត្រីមាសទី៣នៃឆ្នាំ ២០០១។*

[2] *ឆ្នាំ ២000 ។ លីកាដូ " ពន្ធនាគារកម្ពុជា ឆ្នាំ ១៩៩៩: ស្ថានភាពនិងការរំលោភសិទ្ធិមនុស្ស "*

[3] *ឆ្នាំ ២០០១។ "សិទ្ធិមនុស្សនិងពន្ធនាគារកម្ពុជា: ២០០១ របាយាករណ៍សុខភាពលីកាដូ "។*

បញ្ហាចង្អៀតណែននៅតែជាបញ្ហាមួយដ៏ធ្ងន់ធ្ងរដដែល ជាពិសេសនៅពន្ធនាគារខេត្តកំពង់ធំ បន្ទាយមានជ័យ និងក្រុងព្រះសីហនុ ដែលចំនួនអ្នកជាប់ពន្ធនាគារបានកើនឡើងគួរអោយកត់សំគាល់ចាប់តាំងពីរបាយការណ៍ឆ្នាំ១៩៩៩ មក ។ ការប៉ុនប៉ងក្នុងការជួយកាត់បន្ថយភាពចង្អៀតខ្លាំងនោះត្រូវបានអនុវត្ត ដូចជា ការជួសជុលកែលំអពន្ធនាគារដែលមានស្រាប់ជាដើម ប៉ុន្តែវាក៏នៅតែជាបញ្ហាធ្ងន់ធ្ងរដដែល ។ ឧទាហរណ៍ នៅពន្ធនាគារខេត្តកំពង់ធំ អ្នកជាប់ពន្ធនាគារម្នាក់ៗស្នាក់នៅក្នុងទំហំផ្ទៃក្រឡាត្រឹមតែ ០,៩៣ម៉ែត្រក្រឡាតែប៉ុណ្ណោះ ដែលទំហំនេះបានថយចុះពី១,៧ម៉ែត្រក្រឡាក្នុងម្នាក់កាលពីឆ្នាំ១៩៩៨ ។ យោងតាមប្រសាសន៍នាយកពន្ធនាគារបានអោយដឹងថា ពន្ធនាគារនេះត្រូវបានកសាងឡើងសំរាប់ទទួលត្រឹមតែ ៤០នាក់ប៉ុណ្ណោះ ហើយនៅឆ្នាំ២០០១ កន្លងទៅ ពន្ធនាគារនេះបានផ្ទុកពិរុទ្ធជន និង ទណ្ឌិតរហូតដល់ ១២០នាក់ ដែលស្មើនឹង៣ដងនៃចំនួនដែលបានកំណត់ទុកក្នុងពេលកសាងពីដំបូង ។

បញ្ហាមួយដែលតែងតែកើតឡើងជារឿយៗនោះ គឺការឃុំខ្លួនពិរុទ្ធជនលើសនីតិវិធី ដែលផ្ទុយនឹងច្បាប់កម្ពុជាព្រមទាំងច្បាប់អន្តរជាតិផងដែរ ។ នៅពន្ធនាគារខេត្តបន្ទាយមានជ័យ មណ្ឌលកែប្រែទី១ និង មណ្ឌលកែប្រែទី២ ជាមធ្យមមានពិរុទ្ធជន២៧០នាក់ ដែលត្រូវឃុំខ្លួនលើស៦ខែ ដែលជារយៈពេលកំណត់ក្នុងនីតិវិធីពន្ធនាគារកម្ពុជា លេខ៣៤ ចំណុច៤ ។ នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០១ អង្គការលីកាដូបានផ្ញើលិខិតបីច្បាប់ទៅក្រសួងយុត្តិធម៌ ឧត្តមក្រុមប្រឹក្សាអង្គចៅក្រម និង អគ្គព្រះរាជអាជ្ញានៃសាលាឧទ្ធរណ៍ ដើម្បីជំរាបជូននូវបញ្ហាដ៏ធ្ងន់ធ្ងរនេះ ។ នៅពេលដែលអង្គការលីកាដូបានធ្វើអន្តរាគមន៍ក្នុងនាមយុវជនម្នាក់ (សូមអានករណីសិក្សាទី១) ដែលត្រូវបានឃុំខ្លួនជិតមួយឆ្នាំនោះ ទាំងចៅក្រមជំនុំជំរះ និង ចៅក្រមស៊ើបអង្កេតបានលើកឡើងពីបញ្ហាខ្វះថវិកា និង ការងារច្រើនលើសលប់មកធ្វើជាមូលហេតុដែលនាំអោយមានការអនុវត្តន៍បន្តបែបនេះ ។ ឧទាហរណ៍មួយទៀតស្តីអំពីការឃុំខ្លួនលើសនីតិវិធីនេះ អាចលើកយកករណីកងទ័ពសេរីជាតិកម្ពុជា (សូមអានករណីសិក្សាទី២) ដែលក្នុងខណៈឃុំខ្លួនបណ្តោះអាសន្ននោះត្រូវបានឃុំឃាំងសឹងតែមិនអោយមានទំនាក់ទំនងទាល់តែសោះ សូម្បីតែបុគ្គលិកសិទ្ធិមនុស្សក៏មិនអាចចូលជួបបានផង ហើយមានករណីជាច្រើនទៀតដូចជា មេធាវី និងសមាជិកគ្រួសារក៏មិនអាចចូលជួបបានដែរ ។

ការធ្វើទារុណកម្មក៏ជាការរំលោភមួយដ៏ធ្ងន់ធ្ងរបំផុតដែរក្នុងចំណោមសិទ្ធិទាំងឡាយរបស់ពិរុទ្ធជន និង ទណ្ឌិតដែលអង្គការលីកាដូប្រមូលពត៌មានបាន ។ ទោះជាការធ្វើទារុណកម្មដោយឆ្មាំពន្ធនាគារមកលើទណ្ឌិត និង ពិរុទ្ធជនមានការថយចុះនៅក្នុងប៉ុន្មានឆ្នាំកន្លងមកនេះក៏ដោយ ក៏នៅតែកើតមានឡើងដល់ពិរុទ្ធជន និង ទណ្ឌិតមួយចំនួនទៀតដែរ-១,២%នៃពិរុទ្ធជននិងទណ្ឌិតដែលបានសម្ភាសន៍ក្នុងឆ្នាំ២០០១ បានរាយការណ៍ថាពួកគេបានទទួលរងការធ្វើទារុណកម្ម ជាពិសេសទារុណកម្មក្នុងន័យជាការដាក់ទណ្ឌកម្មទៅលើអ្នកដែលបានប្រព្រឹត្តិខុសឆ្គង ឬ ករណីខ្លះទៀតជាការដាក់ទណ្ឌកម្មមកលើពិរុទ្ធជនដែលទើបចូលថ្មី ។ ពិរុទ្ធជនមួយចំនួនធំទៀតបានរាយការណ៍ថា ត្រូវបានធ្វើទារុណកម្មនៅប៉ុស្តិ៍ឃុំឃាំងរបស់នគរបាលមុននឹងត្រូវបញ្ជូនខ្លួនមកដល់ពន្ធនាគារ ។

មរណៈភាពក្នុងពន្ធនាគារក៏នៅតែជាបញ្ហាមួយដែលគួរអោយចាប់អារម្មណ៍ខ្លាំងនៅឡើយ ដែលចោទឡើងពីបញ្ហាការថែទាំសុខភាព និង ស្ថានភាពក្នុងការឃុំឃាំងពិរុទ្ធជន និង ទណ្ឌិតទាំងនោះ ។ ភាគច្រើននៃមរណៈភាពក្នុងពន្ធនាគារក្នុងចំណោម ៥៣ករណី គឺបណ្ដាលមកពីជំងឺ ជាពិសេសជំងឺបៅក្លាយរលួយដែលពាក់ព័ន្ធទៅនឹង HIV/AIDS ។ ប៉ុន្តែក៏មានអ្នកជាប់ពន្ធនាគារបីនាក់ដែរបានធ្វើអត្តឃាត ហើយពីរនាក់ទៀតបានស្លាប់ដោយទាក់ទងទៅនឹងការរងរបួសមុនពេលត្រូវបានបញ្ជូនខ្លួនមកពន្ធនាគារ ។ យ៉ាងហោចណាស់ក៏មានពិរុទ្ធជន និង ទណ្ឌិតចំនួន១០នាក់ ដែលបានស្លាប់ដោយសារជំងឺក្អួតឈាម ដែលមូលហេតុមិនត្រូវអាចគេរកឱ្យឃើញ ។

បញ្ហាចង្អៀតណែនក៏បណ្ដាលមកពីកង្វះនូវការផ្ដល់ឱកាសបញ្ចេញអ្នកទោសមកខាងក្រៅ ដើម្បីស្រូបយកខ្យល់អាកាសដែលពួកគេត្រូវមាន ។ នីតិវិធីពន្ធនាគារបានចែងនូវបទដ្ឋានអប្បបរមាមួយដែលតម្រូវអោយពិរុទ្ធជននិងទណ្ឌិតចេញមកទទួលយកខ្យល់អាកាស១ម៉ោងរៀងរាល់ថ្ងៃ ប៉ុន្តែទោះជាមានការចែងយ៉ាងនេះក្ដី ក៏ពិរុទ្ធជន និង ទណ្ឌិតទាំងនោះត្រូវបានគេអនុញ្ញាតអោយចេញពីបន្ទប់ឃុំឃាំងរយៈពេល១ម៉ោងតែប៉ុណ្ណោះ ក្នុងរយៈពេល៣ទៅ៤ថ្ងៃ(នៅមណ្ឌលកែប្រែទី១) ហើយមានអ្នកទើបចូលមកដល់ថ្មីមួយចំនួនទៀតត្រូវបានគេដាក់អោយនៅក្នុងបន្ទប់ឃុំឃាំងរហូតដល់១ខែ(ពន្ធនាគារតាខ្មៅខេត្តកណ្ដាល) ។ ការពន្យល់បកស្រាយទៅនឹងបញ្ហានោះរបស់នាយកពន្ធនាគារបានលើកឡើងពីបញ្ហាកង្វះបុគ្គលិកការពារពិរុទ្ធជន និង ទណ្ឌិតទាំងនោះនៅខាងក្រៅបន្ទប់ឃុំឃាំង ។

ការសាកសួរសុខទុក្ខពិរុទ្ធជន និង ទណ្ឌិត ពីសំណាក់សមាជិកគ្រួសារត្រូវបានជួបការលំបាកខ្លាំងដោយសារអំពើពុករលួយ ។ ជាឧទាហរណ៍ អ្នកទៅសួរសុខទុក្ខនៅពន្ធនាគារមណ្ឌលកែប្រែទី១ បានរាយការណ៍ថាពួកគេត្រូវចំណាយថវិកាពីរឬបីពាន់រៀលនៅតាមចំណុចត្រួតពិនិត្យមួយចំនួននៅច្រកចូលទៅក្នុងពន្ធនាគារនោះ ។ ស្ថានភាពពន្ធនាគារនៅឆ្នាំ២០០១ នេះបានបន្តកើតឡើងនូវបញ្ហាស្ថានភាពសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ហើយជាផ្នែកមួយតម្រូវអោយរាជរដ្ឋាភិបាលកម្ពុជាចាត់វិធានការណ៍ដោះស្រាយជាបន្ទាន់ ។

## ចំនួនពិរុទ្ធជននិងទណ្ឌិត និង ទីកន្លែងចង្អៀត

ចំនួនពិរុទ្ធជន និង ទណ្ឌិតក្នុងពន្ធនាគារកម្ពុជាបានបន្តកើនឡើងឥតឈប់ឈរ ព្រមទាំងបានរក្សានូវកំណើនចំនួនយ៉ាងខ្លាំងតាមរបាយការណ៍អង្គការលីកាដូ នៅក្នុងចំណោមពន្ធនាគារដែលអង្គការលីកាដូបានសង្កេតឃើញចាប់តាំងពីឆ្នាំ១៩៩៦កន្លងមក។

នៅក្នុងខែធ្នូឆ្នាំ២០០១ មានពិរុទ្ធជននិងទណ្ឌិតចំនួន៥.០៨៣ នាក់ ក្នុងពន្ធនាគារដែលមាននៅក្នុងរបាយការណ៍នេះមានការកើនឡើងរហូតដល់ទៅ៤៧១នាក់ (១០%)បើប្រៀបធៀបទៅនឹងខែធ្នូឆ្នាំ២០០០។ ស្ត្រី(រួមទាំងស្ត្រីពេញវ័យនិងកុមារ)មានត្រឹមតែ៩.៩% នៃចំនួនពិរុទ្ធជននិងទណ្ឌិតទាំងអស់តែប៉ុណ្ណោះ ឬស្មើ

នឹង ៣០២ នាក់ ។ អនីតិជន (ប្រុសនិងស្រី) ដែលមានអាយុពី១៣ ដល់១៨ឆ្នាំ មាន៤,៥% នៃចំនួនពិរុទ្ធជន និងទណ្ឌិតទាំងអស់ ឬស្មើនឹង២២៩ នាក់ (សូមមើលតារាងរូបទី១)

**តារាងរូបទី ១**




អង្គការលីកាដូបានធ្វើការសង្កេតមើលជាប្រចាំព្រមទាំងសម្ភាសន៍នៅក្នុងពន្ធនាគារចំនួន១៦កន្លែង ចាប់តាំងពីខែមេសា ឆ្នាំ១៩៩៦ កន្លងមក ។ នៅក្នុងពន្ធនាគារទាំងនោះបានមានការកើនឡើងនូវចំនួនពិរុទ្ធជននិងទណ្ឌិតរហូតដល់២.៣៥៤នាក់ ឬ ស្មើនឹង១៤១% ក្នុងរយៈពេលប្រាំឆ្នាំកន្លះ ចាប់តាំងពីខែមេសាឆ្នាំ១៩៩៦ រហូតដល់ខែធ្នូ ឆ្នាំ២០០១ នេះ ។

**តារាងរូបទី២**




តារាងតួលេខខាងលើបង្ហាញនូវកំណើននៃចំនួនពិរុទ្ធជន និង ទណ្ឌិតនៅក្នុងពន្ធនាគារទាំង១៦[4] ដែលអង្គការលីកាដូបានធ្វើការសង្កេតមើលជាប្រចាំចាប់តាំងពីឆ្នាំ១៩៩៦ កន្លងមក ។ ទិន្នន័យនីមួយៗគឺចាប់ពីខែមេសា ឆ្នាំ១៩៩៦-ខែវិច្ឆិកា ឆ្នាំ១៩៩៧-ខែធ្នូ ឆ្នាំ១៩៩៨-ខែធ្នូ ឆ្នាំ១៩៩៩-ខែធ្នូ ឆ្នាំ២000 និង ខែធ្នូ ឆ្នាំ២០០១ នេះ ។

---

[4] *មណ្ឌលកែប្រែទី ១ (តេ៣) PJ ទួលស្លែង មណ្ឌលកែប្រែទី ២ (ព្រៃស) កំពង់ធំ កំពង់ចាម សៀមរាប បន្ទាយមានជ័យ បាត់ដំបង ពោធិសាត់ កំពង់ឆ្នាំង កំពត ក្រុងព្រះសីហនុ កំពង់ស្ពឺ ព្រៃវែង និង ស្វាយរៀង ។*

ក្នុងអំឡុង ២-៣ ឆ្នាំ កន្លងទៅនេះ មានការខំប្រឹងប្រែង ដើម្បីជួយសម្រួលដល់ការកើនឡើងនូវចំនួនពិរុទ្ធជន និង ទណ្ឌិតក្នុងពន្ធនាគារកម្ពុជា ។ គំរោងកម្មវិធីអូស្រ្តាលីនៃយុត្តិធម៌ព្រហ្មទណ្ឌកម្ពុជា បានជួសជុលកែលំអពន្ធនាគារនៅកំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពត និងមណ្ឌលកែប្រែទី២ ព្រមទាំងបានជួយកសាងជញ្ជាំងបន្ទប់ឃុំឃាំងឡើងវិញនៅពន្ធនាគារទាំងប្រាំកន្លែងនេះ បានកសាងប្រព័ន្ធទឹកស្អាត កន្លែងស្នាក់នៅសំរាប់អ្នកគ្រប់គ្រង ព្រមទាំងការិយាល័យពន្ធនាគារទៀតផង ។ មូលនិធិដែលបានផ្តល់មកពីម្ចាស់មូលនិធិអូស្រ្តាលីបានកសាងអគារថ្មីនៅក្នុងពន្ធនាគារកំពង់ធំ ដែលកសាងដោយរាជរដ្ឋាភិបាលតាមរយៈអង្គការលីកាដូ ។ ពន្ធនាគារមណ្ឌលកែប្រែទី១ដែលពីដើមហៅថា (តេ៣) និងពន្ធនាគារខេត្តសៀមរាបត្រូវបានរុះរើចេញហើយកសាងនៅកន្លែងផ្សេង ហើយពន្ធនាគារទាំងពីរនេះត្រូវបានផ្តល់ហិរញ្ញវត្ថុដោយក្រុមហ៊ុនប្រេងឥន្ធនៈសូតឺម៉ិច ។

**តារាងទី៣**

| ពន្ធនាគារ | ចំនួនពិរុទ្ធជននិងទណ្ឌិត នៅពេលផ្លាស់ទៅអគារថ្មី (ឆ្នាំ) | ចំនួនពិរុទ្ធជននិងទណ្ឌិតចុងខែធ្នូ ២០០១ | កសាងសំរាប់ដាក់ចំណុះ |
|---|---|---|---|
| កំពង់ធំ | ៣៦ (១៩៩៧) | ៨៩ * | ៤០ |
| មណ្ឌលកែប្រែទី១ (តេ៣) | ៤៩៧ (២០០០) | ១.៣៧៥ | ១.២០០ |
| សៀមរាប | ៣៣៣ (២០០១) | ៤៩០ | ៥០០ |

** ចំនួនពិរុទ្ធជននិងទណ្ឌិតបានថយចុះគួរអោយកត់សំគាល់នៅខែធ្នូ ២០០១ ប៉ុន្តែចំពោះខែផ្សេងៗទៀតនៃឆ្នាំ ចំនួននោះបានឡើងចុះនៅជុំវិញ ១២០ នាក់ ។*

ដើម្បីដោះស្រាយបញ្ហាចង្អៀតណែនខ្លាំងនេះ នៅក្នុងកំឡុងប៉ុន្មានឆ្នាំកន្លងទៅ គេបានរំលែកទណ្ឌិតខ្លះចេញពីពន្ធនាគារមួយចំនួន ដូចជា នៅពន្ធនាគារ បាត់ដំបង កំពង់ធំ យកទៅដាក់ មណ្ឌលកែប្រែទី១ មណ្ឌលកែប្រែទី៣ និងពន្ធនាគាខេត្តសៀមរាប ។ ជាឧទាហរណ៍ នៅពន្ធនាគាខេត្តកំពង់ធំ ដែលជាពន្ធនាគារមួយតូចហើយចាប់តាំងពីឆ្នាំ១៩៩៩ មកដល់ចុងខែធ្នូ ឆ្នាំ២០០១ នេះ គេបានបញ្ជូនទណ្ឌិតចេញចំនួនបួនដង ដើម្បីជួយសម្រួលបញ្ហាចង្អៀតណែនខ្លាំងពេកនៅទីនោះ គេធ្លាប់បានបញ្ជូនអ្នកទោសពីកំពង់ធំម្តងទៅដាក់នៅមណ្ឌលកែប្រែទី១ និង បីដងទៀតទៅដាក់នៅក្នុងមណ្ឌលកែប្រែទី៣ ហើយទោះជាមានការបញ្ជូនចេញក្នុងចំនួននេះក៏ដោយ ក៏នៅតែមិនអាចដោះស្រាយបញ្ហានេះបានដដែល ។ យោងតាមប្រសាសន៍របស់លោកនាយកពន្ធនាគារបានអោយដឹងថា ការសាងសង់អគារឃុំឃាំងសំរាប់អ្នកទោសបុរសមានទំហំផ្ទៃប្រមាណ ៧,៥មx១៥ម ស្មើនឹង (១១២,៥ម៉ែត្រក្រឡា) ដែលសំរាប់អ្នកទោសជាអតិបរមាគឺតែ៤០នាក់ប៉ុណ្ណោះ (មើលតារាងទី៣ខាងលើ) ។ ក្រុមគ្រូពេទ្យលីកាដូបានរាយការណ៍នូវបញ្ហាកើតមានបន្ទាន់មួយនៅក្នុងពន្ធនាគារកាលពីឆ្នាំ១៩៩៨ ដែលទាក់ទងទៅនឹងការរាលដាលនៃជំងឺឆ្លងដែលបណ្តាលមកពីបញ្ហាកង្វះអនាម័យ ការចង្អៀតណែនលើសចំណុះការពន្យារ

ពេលឃុំឃាំងក្នុងបន្ទប់យូរអង្វែង ហើយពេលនោះចំនួនអ្នកទោសមានត្រឹមតែ ៦៧នាក់ប៉ុណ្ណោះ ដូច្នេះទំហំផ្ទៃក្រឡាសំរាប់អ្នកទោសម្នាក់មាន១,៧ម៉ែត្រក្រឡា ។ រយៈពេលយ៉ាងវែងក្នុងឆ្នាំ២០០១ ចំនួនអ្នកទោសបុរសគឺមានប្រហែល ១២០នាក់ ចូរមើលតារាងទី៣ ដូចនេះមានន័យថា អ្នកទោសម្នាក់ត្រូវស្ថិតនៅក្នុងទំហំផ្ទៃ ០,៩៣ ម៉ែត្រកឡាតែប៉ណ្ណោះ ។ តាមការពិត ទំហំផ្ទៃសំរាប់អ្នកទោស ម្នាក់ៗរស់នៅអាចធំជាងនេះបន្តិច ដោយលោកនាយកពន្ធនាគារបានអោយអ្នកទោសមួយចំនួនរស់នៅខាងក្រៅបន្ទប់ឃុំឃាំងជាអចិន្ត្រៃយ៍ តាមរោងក្នុងទីធ្លាពន្ធនាគារ ដើម្បីជួយសម្រួលដល់ភាពចង្អៀតណែននៅក្នុងបន្ទប់ឃុំឃាំងនៃពន្ធនាគារ ។ ក្នុងឆ្នាំ២០០១ ដើម្បីអោយមានកន្លែងរស់នៅធំទូលាយ អ្នកទោសទាំងនោះបានយករបស់របពួកគេមកចងព្យួរទៅនឹងពិដាន ឬជញ្ជាំង ហើយខ្លះទៀតដេកនៅតាមផ្លូវដើរ ។



បញ្ហាចង្អៀតណែននៅក្នុងពន្ធនាគារពុំមែនជាបញ្ហាថ្មីទេ ប៉ុន្តែ វាជាបញ្ហាដែលបន្តកើតមានឥតឈប់ឈរជាក់ស្តែង ដូចដែលរបាយការណ៍ពន្ធនាគាររបស់អង្គការលីកាដូកន្លងមកបានលើកឡើងរួចមកហើយ ឧទាហរណ៍ ដូចជា របាយការណ៍នៅឆ្នាំ១៩៩៩ និង ឆ្នាំ២០០០[5] ជាដើម ។ ក្នុងចំណោមពន្ធនាគារដែលបានលើកឡើងនៅក្នុងរបាយការណ៍ឆ្នាំ១៩៩៩ យើងសង្កេតឃើញថា បញ្ហាចង្អៀតណែននេះនៅតែកើតឡើងនៅពន្ធនាគារខេត្តកំពង់ធំ និង ពន្ធនាគារក្រុងព្រះសីហនុដែលនៅពន្ធនាគារទាំងពីរនោះមានការកើនឡើងនូវចំនួនពិរុទ្ធជន និងទណ្ឌិតគួរអោយកត់សំគាល់ចាប់តាំងពីរបាយការណ៍ឆ្នាំ១៩៩៩ មក ។ លើសពីនេះទៀត ពន្ធនាគារខេត្តបន្ទាយមានជ័យក៏មានបញ្ហាចង្អៀតណែននេះខ្លាំងដែរ ដែលមានចំនួនពិរុទ្ធជននិងទណ្ឌិតដល់ទៅ ២៣៦នាក់ក្នុងខែកញ្ញា ឆ្នាំ២០០១ កន្លងទៅនេះ ។ ចំនួននេះបានលើសពីចំណុះពន្ធនាគារដែលត្រូវបានកសាងឡើងសំរាប់ចំណុះមនុស្សត្រឹមតែ១៥០នាក់ ប៉ុណ្ណោះ ។ បញ្ហាចង្អៀតណែននៅក្នុងពន្ធនាគារជាបញ្ហាមួយដែលត្រូវដោះស្រាយជាបន្ទាន់ដោយនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ ប្រសិនបើមិនបានដោះស្រាយទេនោះ វានឹងបណ្តាលអោយបញ្ហាកាន់តែធ្ងន់ធ្ងរឡើងៗ ព្រមទាំងបណ្តាលអោយមានផលវិបាកដ៏ធ្ងន់ធ្ងរដល់សុខភាព ទណ្ឌិត និង ពិរុទ្ធជន ក៏ដូចជា បញ្ហាសន្តិសុខ និង ស្ថេរភាពរបស់ពន្ធនាគារផងដែរ ។

---

5 *"សូមអានរបាយការណ៍ពន្ធនាគារកម្ពុជា -បញ្ហាសិទ្ធិមនុស្សមួយចំនួន " ខែកញ្ញា ឆ្នាំ ១៩៩៩ និងរបាយការណ៍ពន្ធនាគារ កម្ពុជាឆ្នាំ ១៩៩៩ : ស្ថានភាព និងការរំលោភសិទ្ធិមនុស្ស " ខែកក្កដា ឆ្នាំ ២០០០ ។*

# ការឃុំខ្លួនបណ្តោះអាសន្ន

## *ការឃុំខ្លួនលើសនីតិវិធី*

យោងតាមច្បាប់កម្ពុជា ពិរុទ្ធជនដែលត្រូវឃុំខ្លួនបណ្តោះអាសន្នមិនគួរឃុំអោយលើស ៤ ខែទេ ឬនៅក្នុងកាលៈទេសៈពិសេសខ្លះ អាចឃុំរហូតដល់៦ខែ មុនពេលនាំខ្លួនយកទៅជំរះក្តី ។

នីតិវិធីពន្ធនាគារកម្ពុជា លេខ៣៤ ចំណុច៤ បានចែងថាៈ

*" មិនត្រូវឃុំខ្លួនពិរុទ្ធជនដែលមានអាយុលើស១៨ឆ្នាំ អោយលើសពី៦ ខែដោយពុំមានការជំនុំជំរះក្តីឡើយ "*[6]

ចំណុចនេះក៏បានបញ្ជាក់ថែមទៀតដែរនៅក្នុងនីតិវិធីព្រហ្មទណ្ឌកម្ពុជាក្នុងមាត្រាទី ២១ៈ

*" ជនណាក៏ដោយ ទោះជានៅក្នុងឃុំក្តី ឬ នៅក្រៅឃុំក្តី ត្រូវតែបើកសវនាការជុំនំជំរះមិនអោយលើសពី៦ខែឡើយ ក្រោយពេលត្រូវបានចាប់ខ្លួន"* [7]

រយៈពេលកំណត់នេះ កាន់តែមានភាពតឹងតែងថែមទៀតសំរាប់អនីតិជន ដែលមានអាយុចន្លោះពី ១៣-១៨ឆ្នាំ ដែលយោងតាមនីតិវិធីពន្ធនាគារកម្ពុជាត្រូវឃុំខ្លួនបណ្តោះអាសន្នជាអតិបរមាតែរយៈពេល២ខែ[8] ។

ក្នុងអំឡុងពេល២-៣ឆ្នាំ កន្លងទៅនេះ ការឃុំខ្លួនលើសនីតិវិធី គឺជាបញ្ហាមួយយ៉ាងធ្ងន់ធ្ងរ ជាពិសេសចំពោះពិរុទ្ធជននៅពន្ធនាគារខេត្តបន្ទាយមានជ័យ មណ្ឌលកែប្រែទី១ និងមណ្ឌលកែប្រែទី២ (ពន្ធនាគារ២ចុងក្រោយនេះជាពន្ធនាគារដែលពីមុនហៅថា តេ៣ និង ព្រៃសនៅភ្នំពេញ ) ។ នៅឆ្នាំ២០០១ អង្គការលីកាដូបានផ្ញើលិខិតបីច្បាប់ទៅក្រសួងយុត្តិធមិ ឧត្តមក្រុមប្រឹក្សាអង្គចៅក្រម និង អគ្គព្រះរាជអាជ្ញានៃសាលាឧទ្ធរណ៏ ព្រមទាំងបានចម្លងជូនតុលាការខេត្តបន្ទាយមានជ័យ និង តុលាការក្រុងភ្នំពេញផងដែរ ដើម្បីជំរាបជូនពីបញ្ហាឃុំខ្លួនលើសនីតិវិធីនេះ ។ តារាងលេខទី៥ បង្ហាញនូវចំនួនពិរុទ្ធជនដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្នលើស៦ខែ ដែលជារយៈពេលបានកំណត់នៅក្នុងពន្ធនាគារនីមួយៗនៅក្នុងអំឡុងពេលដែលលីកាដូបានផ្ញើសំបុត្រទាំងនោះ។

***តារាងទី ៥***

| កាលបរិច្ឆេទ | ម១ | ម២ | ប៉ៃហ្សី | បន្ទាយមានជ័យ | សរុប |
|---|---|---|---|---|---|
| ២៩/០១/០១ | ១២៧ | ៨៤ | ៥០ | ៣៦ | ២៩៧ |

---

[6] *ជំពូក ៤ បានចែងបន្ថែមទៀត " នាយកពន្ធនាគារត្រូវជូនដំណឹងជាលាយលក្ខណ៏អក្សរទៅតុលាការមួយខែមុននឹងពិរុទ្ធជនណាម្នាក់ត្រូវបានឃុំខ្លួនក្នុងពន្ធនាគារ៦ខែដោយគ្មានការជុំនំជុំរះ ។ សេចក្តីជូនដំណឹងនោះត្រូវប្រាប់ឈ្មោះពិរុទ្ធជន កាលបរិច្ឆេតចូលពន្ធនាគារ បទល្មើសដែលត្រូវបានចោទ និងធ្វើសំណើសុំកាលបរិច្ឆេទពេលវេលាដែលត្រូវជុំនំជុំរះ ។*

[7] *១៩៩៥ ។ មាត្រាដែលពាក់ព័ន្ធទៅនឹងប្រព័ន្ធយុត្តិធមិ និងច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីដែលអនុវត្តនៅកម្ពុជាក្នុងសម័យអន្តរកាល " មាត្រា ២១ ។*

[8] *សូមអាន នីតិវិធីពន្ធនាគារប្រការ ៣៤.១ ជំពូក ៥ ។*

| | | | | | |
|---|---|---|---|---|---|
| ១៤/០៥/០១ | ១៨២ | ៦៧ | ០ | ៣៨ | ២៨៧ |
| ២០/០៩/០១ | ១៣៩ | ៥០ | ៥០ | ១៦ | ២២៥ |

ករណីសិក្សាខាងក្រោមនេះ ផ្អែកទៅលើការរៀបរាប់ប្រាប់របស់ជនរងគ្រោះ ដែលជាការបង្ហាញនូវទិដ្ឋភាពខ្លះៗពាក់ព័ន្ធនឹងការឃុំខ្លួនលើសនីតិវិធីនៅក្នុងពន្ធនាគារកម្ពុជា ។

## ករណីសិក្សាទី១

ឧទាហរណ៍មួយចំពោះការឃុំខ្លួនលើសនីតិវិធី គឺករណីរបស់យុវជនជិទង់ម្នាក់ដែលមានអាយុ១៧ឆ្នាំ ក្នុងពេលដែលគាត់ត្រូវបានចាប់ខ្លួននៅថ្ងៃទី៣០ ខែមិនា ឆ្នាំ២០០០ ហើយត្រូវបានចោទប្រកាន់ពីបទប្លន់ ។ ចៅក្រមស៊ើបអង្កេតបានបញ្ចប់ការស៊ើបអង្កេតរបស់ខ្លួន ហើយបានបញ្ជូនករណីនោះទៅចៅក្រមជំនុំជំរះនៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០០០ ហើយទោះជាយ៉ាងនេះក្តី ក៏ពិរុទ្ធជនរូបនោះនៅតែមិនទាន់ត្រូវបានតុលាការរាជធានីភ្នំពេញនាំយកមកជំនុំជំរះរហូតមកដល់ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០០១ កន្លងទៅនេះ ដែលស្មើរតែ១៨ខែ ក្រោយពីពេលត្រូវបានចាប់ខ្លួន។ នេះជាការរំលោភទៅនឹងនីតិវិធីពន្ធនាគារកម្ពុជា លេខ៣៤ ចំណុច៥ ដែលបានចែងថា អនីតិជនដែលមានអាយុចន្លោះពី១៣ ទៅ១៨ឆ្នាំ មិនត្រូវឃុំខ្លួនបណ្តោះអាសន្នលើសពី១ខែ ឬលើសពី២ខែទេ ប្រសិនបើអនីតិជននោះត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ[9] ។

នៅពេលដែលយើងសួរចៅក្រមស៊ើបអង្កេត និង ចៅក្រមជំនុំជំរះថា ហេតុអ្វីបានជាករណីនោះត្រូវអូសបន្លាយពេលយូរម្លេះ ចៅក្រមទាំងពីរបានឆ្លើយជាន័យទូទៅ ដោយមិនបានឆ្លើយអោយចំករណីដែលបានសួរនោះទេ ។ ចៅក្រមទាំងពីរនោះបានលើកឡើងពីបញ្ហាការងារច្រើនហួសកំរិត និង បញ្ហាគ្មានថវិកាក្នុងការដឹកជញ្ជូនជនទាំងនោះមកជំនុំជំរះ ជាបញ្ហាចម្បងដែលបណ្តាលអោយមានការឃុំខ្លួនលើសនីតិវិធីដូច្នេះ ព្រមទាំងលើកឡើងថាខាងពន្ធនាគារបានសុំថវិកា២០ដុល្លាក្នុងការដឹកពិរុទ្ធជនម្នាក់មកជំនុំជំរះនៅតុលាការ ។ ហើយករណីនេះបានកើតឡើងដូច្នេះមែននៅពន្ធនាគារមណ្ឌលកែប្រែទី១ មណ្ឌលកែប្រែទី២ និង PJ នៅពេលណាដែលគេត្រូវដឹកជញ្ជូនយកពិរុទ្ធជនទៅជំនុំជំរះនៅសាលាឧទ្ធរណ៍ និង តុលាការកំពូលនៅទីក្រុងភ្នំពេញ។

ចៅក្រមជំនុំជំរះបានសង្កត់ធ្ងន់ថា ពិរុទ្ធជនម្នាក់ត្រូវដឹកទៅ/មកតុលាការច្រើនលើកច្រើនសារ ដើម្បីអោយព្រះរាជអាជ្ញា និង ចៅក្រមស៊ើបអង្កេតធ្វើការសម្ភាសន៍ ហើយបន្ទាប់មកទើបដល់ពេលជំនុំជំរះ ដូច្នេះហើយទើបតុលាការពុំមានលទ្ធភាពចំណាយលើសោហ៊ុយដឹកជញ្ជូនទាំងនោះ ហើយពិរុទ្ធជនត្រូវរង់ចាំរហូតលុះត្រាតែមានអ្នកណាម្នាក់ចេញចំណាយថ្លៃឈ្នួលសំរាប់ដឹកជញ្ជូននោះ ហើយករណីនេះភាគច្រើនគឺសមាជិកគ្រួសារជនជាប់ចោទជាអ្នកបង់ចំណាយសោហ៊ុយនេះ ។

សំណួរលើកឡើងថា អ្នកណាជាអ្នកទទួលបន្ទុកក្នុងការដឹកជញ្ជូនពិរុទ្ធជនទាំងនោះមកសវនាការ ជាច្រើនលើកច្រើនសារ ពួកគេតែងតែបន្ទុកបណ្តក់ទៅវិញទៅមកចំពោះការសួរថា តើអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការដឹកជញ្ជូនពិរុទ្ធជនទាំងនោះមកសវនាការ ។ លោកនាយកពន្ធនាគារជូនកាលលើកឡើងថា កិច្ចការនេះពុំ

[9] *សូមអាននីតិវិធីពន្ធនាគារ លេខ ៣.២ មាត្រា ៥ ។*

មែនជាភារកិច្ចរបស់បុគ្គលិកពន្ធនាគារ( អ្នកនៅក្រោមឱវាទក្រសួងមហាផ្ទៃ) ទេ ប៉ុន្តែវាជាភារកិច្ចរបស់ស្ថាប័នតុលាការ( ដែលស្ថិតនៅក្រោមឱវាទក្រសួងយុត្តិធម៌) វិញ ។ ប៉ុន្តែយ៉ាងហោចណាស់ក៏មានមន្ត្រីជាន់ខ្ពស់ម្នាក់នៃក្រសួងមហាផ្ទៃបានមានប្រសាសន៍បញ្ជាក់ថា កិច្ចការនេះជាភារកិច្ចរបស់បុគ្គលិកក្រសួងលោកដែលត្រូវដឹកជញ្ជូនពិរុទ្ធជនមកតុលាការ ។ នៅក្នុងការអនុវត្តន៍ជាក់ស្តែង មន្ត្រីតុលាការមិនត្រូវដឹកជញ្ជូនពិរុទ្ធជនទេ ។ ហេតុដូច្នេះ ទើបបុគ្គលិកពន្ធនាគារនៅតែបន្តប្រព្រឹត្តិខុសច្បាប់ គឺទារលុយពីពិរុទ្ធជនអោយបង់សោហ៊ុយដឹកជញ្ជូនសំរាប់ខ្លួនគេ ។ ប្រសិនបើពិរុទ្ធជនណាម្នាក់ពុំមានថវិកាសំរាប់បង់ថ្លៃដឹកជញ្ជូនខ្លួនគាត់ទេ នោះតុលាការនឹងត្រូវបើកសវនាការករណីគាត់ដោយកំបាំងមុខ ។ នេះគឺជាការរំលោភនូវសិទ្ធិដែលចែងនៅក្នុងច្បាប់កម្ពុជា និង ច្បាប់អន្តរជាតិដែលតំរូវអោយជនជាប់ចោទត្រូវតែមានវត្តមាននៅក្នុងពេលសវនាការរបស់តុលាការ ព្រមទាំងបង្ហាញនូវមេធាវីការពារក្តីរបស់ខ្លួន ។ ដូចដែលមានចែងនៅក្នុងមាត្រា១០ ជំពូក១ នៃនីតិវិធីព្រហ្មទណ្ឌកម្ពុជាបានចែងថា:

> *"សិទ្ធិពឹងពាក់មេធាវី ឬទីប្រឹក្សា ត្រូវបានធានាជូនជនគ្រប់រូបដែលជាប់ចោទពីបទល្មើសមជ្ឈិម ឬបទល្មើសព្រហ្មទណ្ឌ"*[១០]

សិទ្ធិជនជាប់ចោទដែលត្រូវបានគេរំលោភរួចហើយ ដោយការពន្យាពេលឃុំខ្លួនបណ្តោះអាសន្នលើសនីតិវិធី ដូច្នេះបើជននោះមិនត្រូវបានអនុញ្ញាតអោយមានវត្តមាននៅក្នុងសវនាការទៀត នោះនឹងត្រូវរងការរំលោភសិទ្ធិមួយថែមទៀត ។ នៅពេលដែលបុគ្គលិកអង្គការលីកាដូសម្ភាសន៍ចៅក្រមអំពីការឃុំខ្លួនបណ្តោះអាសន្នលើសនីតិវិធីដែលបានកើតឡើងនៅពន្ធនាគារមណ្ឌលកែប្រែទី១ និង មណ្ឌលកែប្រែទី២ គាត់បានលើកឡើងនូវមូលហេតុបីយ៉ាង: -មូលហេតុទី១ គឺកង្វះមធ្យោបាយក្នុងការដឹកជញ្ជូនពិរុទ្ធជន -មូលហេតុទី២ ពុំមានចៅក្រមគ្រប់គ្រាន់ក្នុងការបើកសវនាការ និង មូលហេតុទី៣ ករណីពិសេសមួយចំនួនតំរូវអោយមានការស៊ើបអង្កេតលើសំណុំរឿងព្រហ្មទណ្ឌដែលស្មុគស្មាញច្រើន ។ នៅតុលាការខេត្តបន្ទាយមានជ័យគេបានលើកឡើងពីបញ្ហាពុំមានចៅក្រមគ្រប់គ្រាន់ ថា ជាមូលហេតុធំបំផុតដែលនាំអោយមានការឃុំខ្លួនបណ្តោះអាសន្នលើសនីតិវិធី ។

បញ្ហាមួយដែលពាក់ព័ន្ធទៅនឹងការឃុំខ្លួនបណ្តោះអាសន្នដែលលើកឡើងជាពិសេសទាក់ទងទៅនឹងឆ្នាំ ២០០១នេះ គឺការប្រព្រឹត្តិលើពិរុទ្ធជនទាំងឡាយដែលពាក់ព័ន្ធទៅនឹងកងទ័ពសេរីជាតិកម្ពុជា (CFF) ។ ករណីសិក្សាខាងក្រោមរៀបរាប់លំអិតអំពីស្ថានភាពដែលជនជាប់ចោទក្នុងក្រុមនេះបានប្រឈមមុខ ។

## ករណីសិក្សាទី ២

ការវាយប្រហារមួយទៅលើអគាររដ្ឋាភិបាលមួយចំនួននៅទីក្រុងភ្នំពេញ ដោយក្រុមមួយដែលគេចោទថាជាក្រុម (CFF) នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០០ បណ្តាលអោយមានការចាប់ខ្លួនមនុស្សយ៉ាងច្រើន

---

[10] *១៩៩៥។ "មាត្រាដែលពាក់ព័ន្ធទៅនឹងប្រព័ន្ធយុត្តិធម៌ និងច្បាប់ព្រមទាំងនីតិវិធីព្រហ្មទណ្ឌដែលអនុវត្តនៅកម្ពុជាក្នុងសម័យអន្តរកាល"* ។

ទាំងនៅក្នុងយប់នៃការវាយប្រហារនោះសប្តាហ៍ ព្រមទាំងខែក្រោយៗមកទៀត ។ ជនជាច្រើនដែលត្រូវបានគេសង្ស័យថាជាសមាជិកក្រុម (CFF) ត្រូវបានឃុំខ្លួនក្រោយការចាប់ជាបន្តបន្ទាប់ ដែលប្រកបដោយជោគជ័យ ហើយត្រូវបានគេចោទពីបទភេរវកម្ម និងប្រើប្រាស់អាវុធខុសច្បាប់ ឬជាសមាជិកកងប្រដាប់អាវុធខុសច្បាប់ ។

ខណៈដែលពួកគេជាប់ឃុំខ្លួនជាបណ្តោះអាសន្ន ពិរុទ្ធជនស្ទើរតែទាំងអស់ត្រូវបានឃុំខ្លួននៅក្នុងការឃុំឃាំងមួយដែលស្ទើរតែពុំមានទំនាក់ទំនងទាល់តែសោះ ដោយគេពុំអនុញ្ញាតអោយបុគ្គលិកអង្គការសិទ្ធិមនុស្សចូលជួប ហើយមានករណីជាច្រើនទៀត សូម្បីតែមេធាវីការពារក្តី និងក្រុមគ្រួសារក៏មិនត្រូវបានអនុញ្ញាតអោយចូលជួបផង ។

មេធាវីការពារក្តីមួយចំនួនមិនត្រូវបានអនុញ្ញាតអោយចូលជួបកូនក្តីទេ ហើយក៏មានខ្លះទៀតត្រូវបានគេបដិសេធមិនអោយចូលទៅជួបកូនក្តីជាច្រើនលើកច្រើនសារ នៅទីបំផុតត្រូវរង់ចាំអស់រយៈពេលជាច្រើនខែទើបត្រូវបានគេអនុញ្ញាតអោយចូលទៅជួបត្រឹមតែ២-៣នាទីប៉ុណ្ណោះ ។ លើសពីនេះទៅទៀត ពិរុទ្ធជន៥០នាក់ ក្នុងចំណោមពិរុទ្ធជនដែលសង្ស័យថាជាសមាជិក (CFF) ១២២នាក់ ត្រូវបានគេឃុំខ្លួនដោយខុសច្បាប់ និង ឃុំឃាំងលើស៦ខែ មុននឹងនាំយកទៅជំនុំជំរះ ។

នៅពេលសវនាការមេធាវីការពារក្តីរបស់ពួកគេបានលើកឡើងពីពេលវេលានៃការឃុំខ្លួនបណ្តោះអាសន្នលើសនីតិវិធីចំពោះកូនក្តីរបស់ពួកគេ ហើយសំណូមពរអោយធ្វើការដោះលែងជាបន្ទាន់ តែករណីនេះត្រូវចៅក្រមជំនុំជំរះបដិសេធ ។

## មរណៈភាពនៅក្នុងពន្ធនាគារ

យោងតាមពត៌មានរបស់អង្គការលីកាដូនៅក្នុងឆ្នាំ២០០១ កន្លងទៅនេះ មានទណ្ឌិតនិងពិរុទ្ធជនស្លាប់ចំនួន៥៣នាក់ ក្នុងនោះមានស្ត្រី១នាក់ និង បុរស៥២នាក់ ។ ភាគច្រើននៃទណ្ឌិតនិងពិរុទ្ធជនដែលស្លាប់ទាំងនោះគឺនៅពន្ធនាគារមណ្ឌលកែប្រែទី១ (តេ៣) ភ្នំពេញមានចំនួន៣០នាក់ សូមមើលតារាងទី៦ខាងក្រោមចំពោះពត៌មានដែលទាក់ទងទៅនឹងមរណភាពរបស់ទណ្ឌិតនិងពិរុទ្ធជននៅឆ្នាំ២០០១ កន្លងទៅនេះ ។

| ពន្ធនាគារ | ចំនួនទណ្ឌិតនិងពិរុទ្ធជនស្លាប់ | ចំនួនទណ្ឌិតនិងពិរុទ្ធជនសរុប ខែធ្នូ/២០០១ | ភាគរយ |
|---|---|---|---|
| បន្ទាយមានជ័យ | ២ | ២១៥ | ០,៩០% |
| បាត់ដំបង | ២ | ៤០១ | ០,៥១% |
| កំពត | ១ | ១៤១ | ០,៧១% |
| កំពង់ចាម | ១ | ២៩១ | ០,៣០% |
| កំពង់ឆ្នាំង | ១ | ១១៣ | ០,៩១ |
| កំពង់ស្ពឺ | ១ | ១៦៩ | ០,៦០% |

| | | | |
|---|---|---|---|
| មណ្ឌលកែប្រែទី២ | ៣ | ២៨៣ | ១,០០% |
| ព្រៃវែង | ១ | ១០៣ | ១,០០% |
| សៀមរាប | ៣ | ៤៩០ | ០,៦០% |
| មណ្ឌលកែប្រែទី១ | ៣០ | ១៣៧៥ | ២,០០% |
| មណ្ឌលកែប្រែទី៣ | ១ | ៥៨២ | ០,២០% |
| តាខ្មៅ | ៧ | ២៨៥ | ២,៤០% |

**តារាងទី ៦**

ទណ្ឌិតនិងពិរុទ្ធជនភាគច្រើនស្លាប់ដោយសារជំងឺ ប៉ុន្តែក៏មាន៣នាក់ស្លាប់ដោយសារធ្វើអត្តឃាតដែរ និង ២នាក់ទៀតស្លាប់ដោយសារការរងរបួសមុននឹងត្រូវបញ្ជូនទៅដល់ពន្ធនាគារ ហើយយើងក៏មិនបានដឹងប្រាកដថាការស្លាប់របស់ពួកគេនោះបានបណ្តាលមកពីការរងរបួសឬយ៉ាងណាទេ។ ចំណុចមួយដែលគួរអោយភ្ញាក់ផ្អើលគឺចំនួនដ៏ច្រើនលើសលប់នៃទណ្ឌិត និង ពិរុទ្ធជនដែលមានជំងឺក្នុងពន្ធនាគារនៅក្នុងឆ្នាំ២០០១ មានអ្នកស្លាប់រហូតដល់២០នាក់ ដែលសង្ស័យឬបញ្ជាក់ច្បាស់ថាបានស្លាប់ដោយសារជំងឺពាក់ព័ន្ធទៅនឹង HIV/AIDS ។ ពិរុទ្ធជន និង ទណ្ឌិត១០នាក់ ទៀតដែលរងទុក្ខវេទនាពីជំងឺឈឺចុករមួលខាងក្នុងពោះយ៉ាងខ្លាំង ឬក្អួតឈាមមុនពេលស្លាប់ ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏គេនៅតែមិនអាចកំណត់បាននូវមូលហេតុនៃជំងឺនេះទេ ។ ក្រុមគ្រូពេទ្យអង្គការលីកាដូបានទទួលដំណឹងស្តីពីមរណភាពរបស់ពិរុទ្ធជន និង ទណ្ឌិតពីលោកនាយកពន្ធនាគារនៅពេលដែលករណីស្លាប់នោះកើតមាន ។ នៅពេលខ្លះដែលអាចធ្វើទៅបាន ក្រុមគ្រូពេទ្យអង្គការលីកាដូក៏ចុះទៅពិនិត្យសាកសពអ្នកទោសនោះក្នុងការប្រមូលពតិមាន ដើម្បីអាចអោយដឹងពីមូលហេតុនៃការស្លាប់នោះ ។

## អំពើទារុណកម្ម

តាមឯកសារដែលប្រមូលបានដោយអង្គការលីកាដូ អំពើទារុណកម្មគឺជាការរំលោភលើមនុស្សយ៉ាងធ្ងន់ធ្ងរមួយ ជាពិសេសទៅលើសិទ្ធិរបស់ទណ្ឌិតនិងពិរុទ្ធជន ។ អំពើទារុណកម្មអាចកើតមាននៅប៉ុស្តិ៍ឃុំឃាំងរបស់នគរបាលក្រោយពេលចាប់ខ្លួនជនណាមួយដែលសង្ស័យថាជាមុខសញ្ញា ឬនៅក្នុងពន្ធនាគារបន្ទាប់ពីជនរងគ្រោះត្រូវបានបញ្ជូនយកទៅដាក់នៅទីនោះ។

នៅឆ្នាំ២០០១ នេះ ចំនួនទណ្ឌិត និងពិរុទ្ធជនដែលរាយការណ៍មកអង្គការលីកាដូថា ពួកគេត្រូវបានទទួលរងការធ្វើទារុណកម្មនៅក្នុងពន្ធនាគារ ឬនៅក្នុងប៉ុស្តិ៍ឃុំឃាំងនគរបាល បញ្ហានេះបានថយចុះបន្តិចបើធៀបទៅនឹងឆ្នាំមុនៗ ។ ពាក់ព័ន្ធទៅនឹងការថយចុះនេះ អាចពន្យល់បានមួយផ្នែកតាមរយៈមូលហេតុមួយដែលជាការពិតដោយបុគ្គលិកស្រាវជ្រាវពន្ធនាគារនៃអង្គការលីកាដូបានធ្វើសម្ភាសន៍ទណ្ឌិត និង ពិរុទ្ធជនតិចតួចណាស់នៅក្នុងឆ្នាំ២០០១នេះ អាស្រ័យដោយមានបញ្ហាក្នុងការទទួលបានការអនុញ្ញាតអោយចូលសង្កេតមើលក្នុងពន្ធនាគារ

មួយចំនួននៅក្នុងអំឡុងពេលខ្លះ ។ របាយការណ៍នោះក៏បានបញ្ជាក់ច្បាស់ផងដែរថា បុគ្គលិកស្រាវជ្រាវពន្ធនាគារអង្គការលីកាដូមិនដែលបានធ្វើការសម្ភាសន៍ជាសម្ងាត់ទេ ឬ ធ្វើការសាកសួរអោយបានស៊ីជំរៅណាមួយដើម្បីកំណត់ថា តើរបាយការណ៍ស្តីពីការធ្វើទារុណកម្មនោះត្រឹមត្រូវដែរឬទេ ។ ប៉ុន្តែ បើនិយាយពីការធ្វើទារុណកម្មនៅក្នុងពន្ធនាគារ យើងក៏មានហេតុផលខ្លះដែលនាំអោយជឿបានដែរថា បើមានការចូលទៅសង្កេតមើលជាប្រចាំពីសំណាក់អង្គការលីកាដូ ឬ អង្គការណាផ្សេងៗទៀតនោះ ការធ្វើទារុណកម្មនឹងអាចថយចុះ ។ ប៉ុន្តែនៅក្នុងប៉ុស្តិ៍ឃុំឃាំងរបស់នគរបាល វាមានហេតុផលតិចតួចណាស់ដែលអាចជឿថា ការធ្វើទារុណកម្មបានថយចុះនោះ ។ អង្គការលីកាដូ និង អង្គការមួយចំនួនទៀតកំពុងតែរៀបចំប្រមូលឯកសារបន្ថែមស្តីពីការធ្វើទារុណកម្មនៅក្នុងប៉ុស្តិ៍ឃុំឃាំងរបស់នគរបាលនេះ ។

ក្នុងចំណោមពិរុទ្ធជន២.៣២៤នាក់ដែលអ្នកស្រាវជ្រាវនៃអង្គការលីកាដូបានសម្ភាសន៍នៅក្នុងឆ្នាំ២០០១កន្លងទៅនេះមានពិរុទ្ធជនទណ្ឌិតចំនួន២៧១នាក់(១១,៧%) ត្រូវបានរាយការណ៍ថា បានទទួលរងការធ្វើទារុណកម្មនៅក្នុងប៉ុស្តិ៍ឃុំឃាំងរបស់នគរបាល និង ចំនួន២៨នាក់ផ្សេងទៀត (១,២%)បានរាយការណ៍ថា ពួកគេត្រូវបានរងការធ្វើទារុណកម្មនៅក្នុងពន្ធនាគារ ។ តារាងរូបទី៧ បង្ហាញនូវភាគរយទណ្ឌិត និង ពិរុទ្ធជនដែលបានរាយការណ៍ ថាពួកគេត្រូវបានទទួលរងទណ្ឌកម្មនៅក្នុងពន្ធនាគារនោះ ។

ស្ថិតិនេះប្រាកដជាមានចំនួនទាបជាងចំនួនដែលបានធ្វើទារុណកម្មពិតប្រាកដ ដោយសារមូលហេតុមួយចំនួន ។ មូលហេតុទី១ គឺការធ្វើទារុណកម្មភាគច្រើនមិនសូវត្រូវបានគេរាយការណ៍ទេ នេះបញ្ជាក់អោយឃើញថា ពិរុទ្ធជន និង ទណ្ឌិតទាំងនោះមិនហ៊ានរាយការណ៍ពីការទទួលរងទារុណកម្មនោះទេ ព្រោះខ្លាចក្រែងមានផលលំបាកដោយសារឆ្មាំពន្ធនាគារនៅថ្ងៃក្រោយ និងដោយសារបុគ្គលិកស្រាវជ្រាវនៃអង្គការលីកាដូមិនអាចធ្វើការសម្ភាសន៍ជាសម្ងាត់បានទេ ។ មូលហេតុទី២ គឺនៅពេលសម្ភាសន៍ ការសួរអំពីការធ្វើទារុណកម្មនោះពុំមែនជាការចាំបាច់ដែលត្រូវតែសួរនោះទេ (មានមួយចំនួនតូចដែលអាចមិនត្រូវបានសួរដោយសារតែបញ្ហាពេលវេលា ឬ ការដាក់កំហិតផ្សេងៗទៀត) ។

**តារាងរូបទី៧**






## ការធ្វើទារុណកម្មក្នុងប៉ុស្តិ៍ឃុំឃាំងរបស់នគរបាល

ការសម្ភាសន៍របស់អ្នកស្រាវជ្រាវពន្ធនាគារនៃអង្គការលីកាដូបានបង្ហាញអោយឃើញថា ចំនួនជាសមាមាត្រដ៏ធំមួយនៃពិរុទ្ធជនដែលបានមកដល់ពន្ធនាគារត្រូវបានទទួលរងការធ្វើទារុណកម្មដោយស្នាដៃនគរបាលក្រោយពេលចាប់ខ្លួន ។ ដូច្នេះការធ្វើទារុណកម្មនេះមិនអាចស្តីបន្ទោសទៅលើបុគ្គលិកពន្ធនាគារបាន ហើយការប្រព្រឹត្តិចំពោះពិរុទ្ធជនរងគ្រោះទាំងនោះនៅក្នុងពន្ធនាគារបានបន្ថែមអោយមានបញ្ហាសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរឡើង ។ ផលប៉ះពាល់ដោយសារការធ្វើទារុណកម្មនេះអាចត្រូវបានបន្ថែមបញ្ហាថែមទៀត ដោយសារកង្វះថ្នាំពេទ្យ ការព្យាបាល ព្រមទាំងការថែទាំផ្សេងៗទៀតនៅក្នុងពន្ធនាគារ ហើយត្រូវបានគេដឹងថា ការធ្វើទារុណកម្មច្រើនតែបានបន្សល់ទុកនូវផលវិបាកដល់ជនរងគ្រោះយ៉ាងយូរអង្វែងទាំងផ្នែករាងកាយ និង ផ្នែកផ្លូវចិត្ត។ លើសពីនេះទៅទៀត សិទ្ធិរបស់ជនដែលរងគ្រោះពីអំពើទារុណកម្មទាំងនេះចំពោះមុខច្បាប់ ប្រហែលជាអាចមានការរំលោភមួយទៀតមកលើសិទ្ធិរបស់ពួកគេនៅក្នុងពន្ធនាគារ ឧទាហរណ៍ ដូចជាការមិនអនុញ្ញាតអោយទៅចូលរួមក្នុងសវនាការ ដើម្បីធ្វើការបំភ្លឺចំពោះមុខតុលាការជាដើម ។

អង្គការលីកាដូ នៅតែមានការខ្វល់ខ្វាយយ៉ាងខ្លាំង ដែលនគរបាលនៅតែបន្តប្រព្រឹត្តិការធ្វើទារុណកម្មនេះឥតឈប់ឈរ ជាពិសេសគឺ ដើម្បីជំរិតយកចំលើយសារភាពពីជនសង្ស័យក្នុងបទល្មើសព្រហ្មទណ្ឌ និងដើម្បីជំរិតទារប្រាក់ពីពួកគេ ឬប្រព្រឹត្តិក្នុងបែបផែនខ្វះយុត្តិធម៌ទៅលើពួកឧក្រិដ្ឋជន ។

គ្រោះថ្នាក់ចំពោះការធ្វើទារុណកម្មដល់ជនដែលត្រូវនគរបាលចាប់ខ្លួន គឺមានការកើនឡើងដោយពួកគេទាំងនោះច្រើនតែត្រូវបានឃុំខ្លួនយ៉ាងតឹងរឹងនៅក្នុងប៉ុស្តិ៍ឃុំឃាំងរបស់នគរបាលព្រមទាំងផ្តាច់ការទាក់ទងទៀតផង នៅក្នុងខណៈនោះគេពុំអនុញ្ញាតអោយសមាជិកគ្រួសារ បុគ្គលិកសិទ្ធិមនុស្ស ឬមេធាវីចូលទៅជួបបានទេ ។ នៅក្នុងប៉ុស្តិ៍ឃុំឃាំងរបស់នគរបាលនេះ មិនដូចនៅក្នុងពន្ធនាគារទេ គេតែងតែបិទមិនអោយអ្នកខាងក្រៅចូលបានទេ ហើយគ្មានឱកាសនឹងអាចធ្វើការពិនិត្យ ឬដឹងបាននូវលក្ខខណ្ឌក្នុងការឃុំឃាំងនោះឡើយ ។ នៅក្នុងឆ្នាំ២០០១ នេះយ៉ាងហោចណាស់ក៏មានករណីមួយដែរ ដែលត្រូវបានធ្វើទារុណកម្មរហូតស្លាប់ ហើយករណីនេះត្រូវបានពិពណ៌នានៅក្នុងករណីសិក្សាខាងក្រោម ។

### ករណីសិក្សាទី៣: មរណៈភាពរបស់លោក អ៊ាត អឿន

នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០១ អ៊ាត អឿន ដែលត្រូវបានគេចោទថាជាចោរលួចក្របីត្រូវបាននគរបាលចាប់ខ្លួននៅស្រុកបាភ្នំ ខេត្តព្រៃវែង ហើយគាត់ក៏ស្លាប់ក្នុងរយៈពេល៣ថ្ងៃក្រោយពេលចាប់ខ្លួននោះដោយសារតែរបួសដែលនគរបាលបានធ្វើទារុណកម្មមកលើរាងកាយគាត់ ។ មុននឹងគាត់ស្លាប់ គាត់បានរាយការណ៍ប្រាប់សាក្សីជាច្រើននូវឈ្មោះនគរបាល៣នាក់ដែលគាត់ចោទថា បានធ្វើទារុណកម្មមកលើគាត់ដែលបណ្តាលអោយគាត់ស្លាប់នោះ ។

របាយការណ៍សាក្សីជាច្រើន ក៏ដូចជារូបថតសាកសពរបស់ អ៊ាត អឿន បានបង្ហាញនូវរបួសនិងស្នាមជាំជាច្រើនដែលក្រុមគ្រូពេទ្យអង្គការលីកាដូបានធ្វើការពិនិត្យ ហើយអង្គការលីកាដូក៏បានបញ្ជូនឯកសារដែលពាក់ព័ន្ធទៅនឹងករណីនេះទៅលោក វេជ្ជបណ្ឌិត រ៉ាគែល រូសារីយ៉ូ ហ្វ៉ាកជូន អ្នកជំនាញការខាងកោសល្យវិច្ច័យនៅសកលវិទ្យាល័យហ្វីលីពីននាទីក្រុងម៉ានីល ហើយដែលលោកបានធ្វើការសន្និដ្ឋានដូចខាងក្រោមៈ

"មូលហេតុជាក់លាក់ និង លក្ខណៈនៃមរណៈភាពរបស់ លោក អ៊ាត អឿននេះ គឺមានការលំបាកក្នុងការកំណត់ណាស់ បើផ្អែកទៅលើឯកសារស៊ើបអង្កេតដែលបានធ្វើកន្លងទៅនេះ ។ ទោះបីជារូបថតបានបង្ហាញនូវរបួសពាសពេញខ្លួនក៏ដោយ ក៏ការវាយតំលៃរបស់យើងនៅមានកំរិតដែរ ។ ជាអកុសល ការពិនិត្យសាកសពក៏មិនត្រូវបានធ្វើ ហើយសាកសពក៏ត្រូវបានបូជាអស់ទៅហើយដែលមិនអាចធ្វើការពិនិត្យបាន ។ ប៉ុន្តែ ដូចដែលបានធ្វើការពិភាក្សាទៅលើអ្វីៗដែលបានរកឃើញកន្លងមក ព្រមទាំងផ្អែកទៅលើការសង្កេតដោយផ្ទាល់ដោយសាក្សីមួយចំនួនទៅលើ អ៊ាត អឿន ក្នុងពេលដែលគាត់នៅជាប់ឃុំឃាំងនោះ យើងអាចនិយាយបានថា គាត់ប្រហែលជាបានរងរបួសជាទម្ងន់ដោយកំលាំងអាវុធមុខទាលយ៉ាងច្រើនលើក្បាល ដងខ្លួន និងអវៈយវៈ ។ ផ្អែកទៅលើពតិមានទាំងឡាយដែលប្រមូលបានពាក់ព័ន្ធទៅនឹងស្ថានភាពមរណៈភាពរបស់គាត់ យើងបានចាត់ទុកថា របួសធ្ងន់ធ្ងរដែលប៉ះពាល់ដល់លលាដ៏ក្បាល គឺជាមូលហេតុធំបំផុតដែលនាំអោយគាត់ស្លាប់ ហេតុដូច្នេះ ករណីនេះត្រូវបានចាត់ទុកថា ជាករណីមនុស្សឃាត ។"

នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ កន្លងទៅនេះ ព្រះរាជអាជ្ញាអមតុលាការខេត្តព្រៃវែងបានធ្វើការចោទប្រកាន់ទៅលើមន្ត្រីនគរបាល២នាក់ ពីបទមនុស្សឃាតដោយចេតនា ដែលករណីនោះមានការជាប់ពាក់ព័ន្ធទៅនឹងមរណៈភាពរបស់ អ៊ាត អឿន ហើយលោកបានបញ្ជូនករណីនោះបន្តទៅចៅក្រមស៊ើបអង្កេត ។ នគរបាលទាំង២នាក់នោះមិនត្រូវបានចាប់ខ្លួន ឬនាំយកមកដាក់ក្នុងការឃុំខ្លួនបណ្តោះអាសន្នឡើយ ។ នគរបាលម្នាក់ទៀតដែលត្រូវបានចោទប្រកាន់ថា បានចូលរួមក្នុងការធ្វើទារុណកម្ម អ៊ាត អឿនដែរនោះ មិនត្រូវបានតុលាការចោទប្រកាន់ទេ ពីព្រោះពុំមានភស្តុតាងគ្រប់គ្រាន់ នេះតាមប្រសាសន៍របស់ព្រះរាជអាជ្ញា ។ ក្នុងកំឡុងពេលកំពុងសរសេររបាយការណ៍នេះ ចៅក្រមស៊ើបអង្កេតក៏កំពុងតែធ្វើការស៊ើបអង្កេតទៅលើករណីនេះដែរ ។ ជាធម្មតាការផ្តន្ទាទោសទៅលើនគរបាលដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើទារុណកម្មនេះកម្រកើតមានណាស់ ។ ការផ្តន្ទាទោសទៅលើករណីដែលជាប់ពាក់ព័ន្ធការធ្វើទារុណកម្មចំពោះពិរុទ្ធជនជាប់ឃុំឃាំងចុងក្រោយបង្អស់ដែលយើងបានដឹងនោះគឺនៅឆ្នាំ១៩៩៧ ដែលករណីនោះ មន្ត្រីនគរបាលរូបនោះត្រូវបានផ្តន្ទាទោសពីបទល្មើសព្រហ្មទណ្ឌកំរិតស្រាល ហើយត្រូវបានកាត់ទោសព្យួរថែមទៀតផងដោយពុំបានជាប់ពន្ធនាគារសូម្បីតែមួយថ្ងៃក៏អត់ដែរ ។

## ការធ្វើទារុណកម្មក្នុងពន្ធនាគារ

ក្នុងកំឡុងពេលប៉ុន្មានឆ្នាំកន្លងទៅនេះ បរិមាណនៃការធ្វើទារុណកម្មដែលប្រព្រឹត្តិឡើងដោយឆ្មាំពន្ធនាគារ

បានមានការថយចុះ ទោះបីជាមិនមានវិធានការណ៍ណាមួយអាចលុបបំបាត់ចោលអោយអស់ក៏ដោយ។ ការធ្វើទារុណកម្មត្រូវបានគេអនុវត្តជាចំបងនៅក្នុងពន្ធនាគារជាលេសដាក់ទណ្ឌកម្មដល់អ្នកណាដែលល្មើសមិនគោរពវិន័យ ឬសន្តិសុខ ជាពិសេសពិរុទ្ធជន ឬទណ្ឌិតណាដែលមានបំណងចង់រត់គេចចេញពីពន្ធនាគារជាដើម។ ប៉ុន្តែការធ្វើទារុណកម្មនេះក៏អាចត្រូវបានគេប្រព្រឹត្តិឡើងក្នុងគោលបំណងផ្សេងៗទៀតដែរ ហើយអ្នកចូលថ្មីគឺជាជនដែលត្រូវបានរងទុក្ខទោសនេះច្រើនជាងគេ ។

ការដាក់ខ្នោះដែលនៅតែបន្តប្រើជាប្រចាំ ហើយទង្វើនេះដែលត្រូវបានច្បាប់កម្ពុជាហាមឃាត់នោះទង្វើបែបនេះគឺចាត់ជាការធ្វើទារុណកម្ម[11] មួយបែបដែលត្រូវបានគេប្រើយ៉ាងសាមញ្ញ ។ ច្បាប់អន្តរជាតិតាមរយៈ *បទបញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រងអ្នកទោស* ដែលត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅឆ្នាំ១៩៥៥ បានកំណត់ថាការប្រើឧបករណ៏ដែលត្រូវបានហាមឃាត់ទាំងនេះគឺជាអំពើខុសច្បាប់ដែរ ។

> *"ឧបករណ៏ទប់ទល់នឹងអ្នកទោសដូចជាខ្នោះដៃ ច្រវាក់ ដែកឃ្នាប និងអាវធំ (គឺអាវធំម្យ៉ាងដែលរឹងកាលណាពាក់ឱ្យអ្នកទោស ហើយអ្នកទោសមិនអាចកំរើកខ្លួនបានឡើយ) មិនអោយកំរើករួច មិនត្រូវប្រើប្រាស់ជាការដាក់ទណ្ឌកម្មឡើយ ។ លើសពីនេះទៅទៀតច្រវាក់ ឬ ដែកឃ្នាបក៏មិនត្រូវបានអនុញ្ញាតអោយប្រើជាការទប់ទល់ឡើយ"។*[12]

នៅក្នុងឆ្នាំ ២០០១ នេះ មានការប្រើប្រាស់ខ្នោះនៅពន្ធនាគារ ក្រុងព្រះសីហនុ និង ពន្ធនាគារខេត្តកំពង់ធំ ។ ប្រហែលជា១/៣នៃទណ្ឌិត និង ពិរុទ្ធជន បានរាយការណ៏ប្រាប់ថា ពួកគេដែលបានរងទារុណកម្មនោះគឺជាអ្នកជាប់នៅពន្ធនាគារក្រុងព្រះសីហនុ ។ យោងតាមការសម្ភាសន៏ពិរុទ្ធជន និង ទណ្ឌិតជាច្រើនឆ្នាំកន្លងមកការព្រួយបារម្ភយ៉ាងខ្លាំងនៅពន្ធនាគារក្រុងព្រះសីហនុនោះ គឺការអនុវត្តន៏នូវការបំបាក់ជំហរពិរុទ្ធជនដែលទើបចូលមកដល់ថ្មីៗដោយការវាយឬទាត់ធាក់នៅពេលចូលមកដល់ក្នុងពន្ធនាគារភ្លាមៗ ។ ការអនុវត្តបែបនេះនៅក្នុងពន្ធនាគារគឺប្រហែលជាមានគោលដៅ ដើម្បីបំបាក់ជំហរពិរុទ្ធជនដែលទើបចូលថ្មីអោយ *"ទន់ភ្លន់រាបសារ"* ហើយដើម្បីអោយអ្នកទាំងនោះស្តាប់បង្គាប់ឆ្មាំពន្ធនាគារ ។ កន្លងមកអង្គការលីកាដូក៏បានលើកឡើងនូវបញ្ហានេះនៅចំពោះមុខនាយកពន្ធនាគារដែលបានសន្យាថានឹងបញ្ឈប់លែងអោយមានទង្វើបែបនេះកើតឡើងទៀត ។

ច្បាប់ព្រហ្មទណ្ឌ និង ច្បាប់គ្រប់គ្រងពន្ធនាគាររបស់កម្ពុជាបានចែងយ៉ាងច្បាស់ ស្តីពីការហាមប្រាមក្នុងការប្រើប្រាស់អំពើទារុណកម្មទោះបីមានមូលហេតុអ្វី ឬ តាមរូបភាពណាក៏ដោយរួមទាំងការដាក់ទណ្ឌកម្មផង

---

[11] *នីតិវិធីពន្ធនាគារកម្ពុជាប្រការ ២៥.១ ជំពូក ៣-៥ "ការដាក់ខ្នោះមិនត្រូវបានអនុញ្ញាតអោយប្រើជាការដាក់ទណ្ឌកម្មឡើយ ។ ការដាក់ខ្នោះនឹងត្រូវបានអនុញ្ញាតអោយប្រើដរាបណាមានការអនុញ្ញាតពីប្រធានពន្ធនាគារហើយមិនត្រូវប្រើនៅក្នុងរយៈពេលវែងជាងពេលវេលាចាំបាច់ទេ។ ការដាក់ខ្នោះនឹងត្រូវអនុញ្ញាតអោយប្រើសំរាប់តែពិរុទ្ធឬទណ្ឌិតណាដែល អាចបណ្តាលអោយមានគ្រោះថ្នាក់ដល់ខ្លួនឯងឬដល់អ្នកដទៃ ។"*

[12] *១៩៥៥។ បទបញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាបគ្រប់គ្រងចំពោះអ្នកទោស ។ ចំណុចទី ៣៣ ជំពូក ១។*

ដែរ ។ ប៉ុន្តែ ទោះជាមានច្បាប់ចែងបែបនេះក្តី ក៏មិនដែលមានមន្ត្រីពន្ធនាគារណាម្នាក់ត្រូវបានផ្តន្ទាទោសពីការប្រព្រឹត្តិអំពើទារុណកម្មនេះឡើយក្នុងកំឡុងពេល១ទសវត្សរកន្លងមកនេះ ។ ករណីជាក់ស្តែងមួយទាក់ទិនទៅនឹងការផ្តន្ទាទោសឆ្មាំពន្ធនាគារប្រាំនាក់នៅកំពង់ចាម ដែលត្រូវបានចោទប្រកាន់ពីបទធ្វើទារុណកម្មលើអ្នកទោស៥នាក់ យ៉ាងធ្ងន់ធ្ងរនៅខែធ្នូ ឆ្នាំ១៩៩៩ (ប្រើប្រាស់ទារុណកម្មដោយការវាយដំនឹងត្បូងចបរហូតដល់សន្លប់បាត់ស្មារតី) ហើយរហូតមកដល់ឆ្នាំ២០០១ ករណីនេះនៅតែមិនទាន់ត្រូវបានជុំនុំជំរះនៅឡើយ ។

ដើម្បីកាត់បន្ថយការធ្វើទារុណកម្មនៅក្នុងពន្ធនាគារកម្ពុជាអោយបានច្រើនថែមទៀត កត្តាសំខាន់គឺតម្រូវអោយអង្គការលីកាដូ និង អង្គការសិទ្ធិមនុស្សផ្សេងៗទៀតមានលទ្ធភាពក្នុងការបន្តសង្កេតមើលស្ថានភាពទូទៅក្នុងពន្ធនាគារយ៉ាងជិតដល់ ។ ហើយក្នុងកំឡុងពេលអនុវត្តការសង្កេតមើលនេះចាំបាច់ត្រូវអនុញ្ញាតអោយអង្គការទាំងនោះធ្វើការរបស់ខ្លួនប្រកបដោយភាពសម្ងាត់គ្រប់គ្រាន់ ធ្វើការសម្ភាសន៍ជាមួយទណ្ឌិតឬពិរុទ្ធជនដែលអាចរក្សាបាននូវការសម្ងាត់ល្អ និង ធានាអោយអ្នកផ្តល់ការសម្ភាសន៍មានអារម្មណ៍ថាមានសុវត្ថិភាព និងទំនុកចិត្តអោយបានច្រើនតាមលទ្ធភាពដែលអាចធ្វើទៅបានក្នុងការរាយការណ៍ពីករណីរំលោភបំពាននោះ ដោយមិនមានការភ័យខ្លាចពីការសងសឹករបស់សំណាក់ឆ្មាំឬបុគ្គលិកពន្ធនាគារវិញ ។ រហូតមកដល់ពេលនេះអ្នកស្រាវជ្រាវពន្ធនាគារនៃអង្គការលីកាដូ ក៏នៅតែជួបប្រទះបញ្ហាក្នុងការធានាអោយមានការសម្ងាត់ក្នុងការសម្ភាសន៍ពិរុទ្ធជន និង ទណ្ឌិតនៅឡើយ ។

# ការបន្ទូរបរិយាកាស និង ការសួរសុខទុក្ខរបស់សមាជិកគ្រួសារ

## ការបន្ទូរបរិយាកាស

ការមិនបានអនុញ្ញាតអោយពិរុទ្ធជន និង ទណ្ឌិតបានចេញក្រៅបន្ទប់ឃុំឃាំង ដើម្បីស្រូបយកខ្យល់អាកាស និង ត្រូវកំដៅថ្ងៃយ៉ាងហោចណាស់មួយម៉ោងក្នុងមួយថ្ងៃ ដូចដែលមានចែងនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងពន្ធនាគារនោះ វានៅតែជាបញ្ហាបន្តរហូតមកដល់ឆ្នាំ២០០១ នេះ ។ នៅក្នុងមាត្រាទី២១ ជំពូកទី១នៃច្បាប់ *បទបញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រងចំពោះអ្នកទោស* បានចែងថា :

*"អ្នកទោសគ្រប់រូបដែលមិនបានចេញទៅធ្វើការនៅខាងក្រៅមន្ទីរឃុំឃាំងទេនោះ ត្រូវមានឱកាសហាត់ប្រាណនៅក្នុងទីធ្លាស្រឡះយ៉ាងតិចមួយម៉ោងជារៀងរាល់ថ្ងៃ ប្រសិនបើធាតុអាកាសអនុញ្ញាត ។"*[១៣]

ជាច្រើនឆ្នាំកន្លងមកហើយ ពន្ធនាគារមណ្ឌលកែប្រែទី១ ពន្ធនាគារ PJ ពន្ធនាគារតាខ្មៅ ខេត្តកណ្តាលនិងពន្ធនាគារខេត្តកំពង់ធំ គឺជាពន្ធនាគារដែលបានជួបប្រទះនូវបញ្ហាខាងលើនេះយ៉ាងច្រើនជាទីបំផុត ។ នាយកពន្ធនាគារនៅតែបន្តដោះសារថា កត្តានេះបណ្តាលមកពីចំនួនពិរុទ្ធជន និង ទណ្ឌិតច្រើនលើសបរិមាណកំណត់ហើយពុំមានឆ្មាំនិងមន្ត្រីពន្ធនាគារគ្រប់គ្រាន់ ដើម្បីឃ្លាំមើលការពារពិរុទ្ធជន និង ទណ្ឌិតទាំងនោះនៅពេលអោយ

---

[13] *១៩៩៥ ។ បទបញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រងចំពោះអ្នកទោស ។ មាត្រាទី ២១ ជំពូក ទី ១ ។*

ពួកគេចេញក្រៅបន្ទប់ឃុំឃាំងម្តងៗ ។ ហេតុដូច្នេះហើយទើបពន្ធនាគារបានដាក់វេនអោយពិរុទ្ធជន និង ទណ្ឌិតទាំងនោះចេញដើម្បីធ្វើការហាត់ប្រាណ ឬ គ្រាន់តែអោយបានចេញផុតពីបន្ទប់ឃុំឃាំងប៉ុណ្ណោះ ។ នៅពន្ធនាគារតាខ្មៅ ខេត្តកណ្តាល ពិរុទ្ធជនដែលទើបចូលមកដល់ថ្មី គឺជាអ្នកដែលត្រូវទទួលរងការឃុំក្នុងបន្ទប់ឃុំឃាំងបែបនេះច្រើនជាងគេរហូតដល់មានអ្នកខ្លះត្រូវបានគេឃុំរយៈពេលមួយខែ ដោយមិនត្រូវបានអនុញ្ញាតអោយចេញមកក្រៅ ដើម្បីធ្វើការហាត់ប្រាណឬត្រូវកំដៅថ្ងៃទាល់តែសោះ ។ នៅក្នុងពន្ធនាគារមណ្ឌលកែប្រែទី១ដែលមានទណ្ឌិត និង ពិរុទ្ធជនរហូតដល់១.៣៧៥នាក់ នៅខែធ្នូ ឆ្នាំ២០០១ នោះ មួយថ្ងៃៗគេបានអនុញ្ញាតអោយទណ្ឌិត និង ពិរុទ្ធជនប្រមាណ៤00នាក់ ចេញមកក្រៅដើម្បីធ្វើការហាត់ប្រាណ ទាំងពេលព្រឹកនិងពេលរសៀល ហើយមានរយៈពេលប្រមាណជាមួយម៉ោង ។ តាមការពិតទៅ ទណ្ឌិតនិងពិរុទ្ធជនភាគច្រើនត្រូវបានអនុញ្ញាតអោយចេញក្រៅបន្ទប់ឃុំឃាំងត្រឹមតែរយៈពេលមួយម៉ោងប៉ុណ្ណោះក្នុងកំឡុងពេលវៀងរាល់បីឬបួនថ្ងៃម្តង ។



កង្វះការហាត់ប្រាណ និង កង្វះការទទួលពន្លឺថ្ងៃជាប្រចាំបណ្តាលអោយមានជំងឺសើរស្បែក និង បញ្ហាសុខភាពផ្សេងៗទៀតដល់ពិរុទ្ធជន និង ទណ្ឌិត ជាពិសេសនៅពេលដែលមានស្ថានភាពរស់នៅចង្អៀតណែន[១៤] ។

## ការសួរសុខទុក្ខរបស់សមាជិកគ្រួសារ

សមាជិកគ្រួសាររបស់ពិរុទ្ធជន និង ទណ្ឌិតជាច្រើនបានរាយការណ៍ថា គេត្រូវសូកលុយឆ្មាំពន្ធនាគារដើម្បីបានចូលសួរសុខទុក្ខបងប្អូនដែលជាប់នៅក្នុងពន្ធនាគារនោះ ដែលទង្វើនេះគឺជាការរំលោភលើច្បាប់គ្រប់គ្រងពន្ធនាគារ និង បទដ្ឋានអន្តរជាតិ ។ នៅក្នុងនីតិវិធីពន្ធនាគារកម្ពុជា លេខ៨ ចំណុច៤ បានចែងថា :

14 *ចំពោះពត៌មានលំអិតបន្ថែម សូមអានរបាយការណ៍ "សិទ្ធិមនុស្សនិងពន្ធនាគារកម្ពុជា: ២០០១ របាយការណ៍សុខភាព អង្គការលីកាដូ" -លីកាដូ ២០០១ ។*

*"ពិរុទ្ធជននិងទណ្ឌិតទាំងអស់មានសិទ្ធិក្នុងការទទួលការមកសួរសុខទុក្ខដូចជាគ្រួសារ ឬមិត្តភ័ក្តិក្នុងរយៈពេលយ៉ាងហោចណាស់មួយម៉ោងក្នុងមួយសប្តាហ៍តាមពេលវេលាបានកំណត់របស់បញ្ញត្តិពន្ធនាគារ ដែលនាយកពន្ធនាគារជាអ្នកកំណត់ ។"*[១៥]

លើសពីនេះទៅទៀត នីតិវិធីពន្ធនាគារកម្ពុជា លេខ៨ ចំណុច១៨ បានចែងយ៉ាងច្បាស់ថា:

*"នាយកពន្ធនាគារ មន្ត្រីពន្ធនាគារ ឬឆ្មាំពន្ធនាគារ មិនត្រូវទទួលលុយឬអំណោយណាមួយពីភ្ញៀវទាំងឡាយដែលមកសួរសុខទុក្ខអ្នកទោសដើម្បីបានទទួលសិទ្ធិចូលសួរសុខទុក្ខនោះទេ ។"*

បញ្ហានេះកន្លងមកអង្គការលីកាដូក៏បានរាយការណ៍រួចមកហើយដែរ ប៉ុន្តែហាក់ដូចជាពុំមានសញ្ញាណាមួយថយចុះទាល់តែសោះរហូតមកដល់សព្វថ្ងៃនេះ ។ គ្រួសារអ្នកទោសជាច្រើនជាអ្នកក្រីក្រ និង មិនអាចមានលុយសំរាប់សូកប៉ាន់បែបនេះទេ ដូច្នេះមានន័យថា ពួកគេមិនអាចចូលសួរសុខទុក្ខសមាជិកគ្រួសារគេអោយបានច្រើនដងតាមដែលគេចង់បាននោះទេ ។ ឧទាហរណ៍ នៅពន្ធនាគារមណ្ឌលកែប្រែទី១ព្រៃស តាមការសម្ភាសន៍របស់អ្នកស្រាវជ្រាវពន្ធនាគារនៃអង្គការលីកាដូជាមួយនឹងពិរុទ្ធជន-ទណ្ឌិត និង សមាជិក្រុមគ្រួសារដែលមកសួរសុខទុក្ខបានប្រាប់អោយដឹងថា អ្នកមកសួរសុខទុក្ខត្រូវចំណាយថវិកាយ៉ាងហោច ២៣.០០០រៀល ដើម្បីបានការអនុញ្ញាតចូលសួរសុខទុក្ខសមាជិកគ្រួសារម្តងៗ ។ ខាងក្រោមនេះ គឺជាបញ្ជីនៃការចំណាយ ដើម្បីសូកតាមកន្លែងនិមួយៗនិងកន្លែងដែលត្រូវសូករបស់អ្នកមកសួរសុខទុក្ខនៅពន្ធនាគារមណ្ឌលកែប្រែទី១ ព្រៃស ។

| | | |
|---|---|---|
| ១ | កន្លែងត្រួតពិនិត្យទី១ច្រកចូលពន្ធនាគារ | ២.០០០ រៀល ឬប្រហែល ០,៥០ ដុល្លា[១៦] |
| ២ | ច្រកចូលអគារពន្ធនាគារ | ២.០០០ រៀល ឬប្រហែល ០,៥០ ដុល្លា |
| ៣ | ការិយាល័យរដ្ឋបាល | ១៥.០០០ រៀល ឬប្រហែល ៤ ដុល្លា |
| ៤ | ការិយាល័យអចិន្ត្រៃយ៍ | ២.០០០ រៀល ឬប្រហែល ០,៥ ដុល្លា |
| ៥ | បន្ទប់ទទួលភ្ញៀវៈ នៅទីនេះមានបន្ទប់ពីរ បន្ទប់១ជាបន្ទប់ដែលគេអាចនិយាយផ្ទាល់មាត់ជាមួយគ្នា ហើយបន្ទប់មួយទៀតជាបន្ទប់ដែលគេនិយាយគ្នាតាមទូរស័ព្ទ-ដូច្នេះដើម្បីបានចូលបន្ទប់ទី១ត្រូវសូកលុយច្រើន ។ លើសពីនេះទៅទៀត ភ្ញៀវក៏ត្រូវចំណាយលុយថែមទៀតដែរប្រសិនបើគេចង់ជួប | ២.០០០ រៀល ឬប្រហែល ០,៥ ដុល្លា |

---

[15] *១៩៩៨ ។ "នីតិវិធីពន្ធនាគារ" របស់នាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៥ ខែឧសភា នីតិវិធីពន្ធនាគារកម្ពុជា លេខ៨ ចែងពី "ការសួរសុខទុក្ខអ្នកទោស" ។*

[16] *នៅពេលសរសេររបាយការណ៍នេះ ១ ដុល្លាស្មើនឹង ៣.៩០០ រៀល អត្រាប្តូរប្រាក់អាចឡើងចុះខុសគ្នាប្រហែល១០សេន ។*

| | | |
|---|---|---|
| | និយាយគ្នាអោយបានយូរ ។ | |
| ៦ | ច្រកចូលខាងក្នុង ទៅក្នុងពន្ធនាគារៈ ត្រង់ចំណុចនេះគេត្រូវសូកម្តងទៀតបើចង់ហុចម្ហូបអាហារអោយអ្នកទោស ។ | ១.៥០០ រៀល -២.០០០ រៀល ឬហែល ០,៤ ដុល្លា-០,៥ ដុល្លា |
| ៧ | ច្រកចូលបន្តទៅក្នុងពន្ធនាគារៈ ត្រង់ចំណុចនេះមានការត្រួតពិនិត្យមើលម្ហូបអាហារដែលទទួលបាន ហើយត្រូវឆ្នាំដកហូតយកមួយភាគទៀត។ | ចំណីអាហារដកហូតមួយភាគ |

លើសពីនេះទៀត ការសម្ភាសន៍ជាមួយសមាជិកគ្រួសារដែលមកសួរសុខទុក្ខបានលាតត្រដាងអោយឃើញ អំពើពុករលួយច្រើនថែមទៀតនៅក្នុងពន្ធនាគារ មណ្ឌលកែប្រែទី១នេះ គឺភាគច្រើនត្រូវបានប្រព្រឹត្តិទៅលើអ្នកដែលទើបចូលមកដល់ថ្មី ជាពិសេសនៅក្នុងខែដំបូងនៃការឃុំឃាំងរបស់ពួកគេ ។ យោងតាមមន្ត្រីពន្ធនាគារបានអោយដឹង ភ្ញៀវដែលមកសួរសុខទុក្ខអ្នកដែលទើបមកដល់ថ្មីៗនោះច្រើនតែមកធ្វើការសម្រុះសម្រួលក្នុងការស៊ើបអង្កេតបទល្មើសដែលត្រូវផ្តន្ទាទោស ។ ប៉ុន្តែនៅក្នុងករណីខ្លះ ក៏នៅមានគេអាចចូលសួរទុក្ខបានដែរនៅក្នុងខែដំបូងនេះ បើសិនសមាជិកក្រុមគ្រួសារនោះហ៊ានចំណាយថវិកាពី ៥០-១០០ដុល្លា (១៩៥.០០០ -៣៩០.០០០ រៀល) ។

គេគួរកត់សំគាល់ថា ទីតាំងពន្ធនាគារ ដូចជា មណ្ឌលកែប្រែ ម១ ម២ ម៣ និង ពន្ធនាគារខេត្តសៀមរាប (ដែលមានចំងាយឆ្ងាយពីក្រុង) ធ្វើអោយសមាជិកគ្រួសារគេជួបការលំបាកយ៉ាងខ្លាំងក្នុងការផ្តល់ម្ហូបអាហារចាំបាច់បន្ថែមផ្សេងទៀត ។ ដូច្នេះកត្តាដែលសមាជិកគ្រួសាររបស់ពិរុទ្ធ និង ទណ្ឌិតអាចធ្វើដំណើរមកដល់ពន្ធនាគារមណ្ឌលកែប្រែទី១នេះ ហើយត្រូវសូកប៉ាន់គេ និង អោយចំណីអាហារដែលយកមកមួយចំណែកទៀត នោះវាកាន់តែធ្វើអោយស្ថានភាពរបស់ពួកគេកាន់តែស្ថិតក្នុងសភាពមួយដែលកាន់តែធ្ងន់ធ្ងរខ្លាំងថែមទៀត ។

## សេចក្តីសន្និដ្ឋាន

កំណើនដោយគ្មានប្រែប្រួលនៃអ្នកចំណូលថ្មីនៅក្នុងពន្ធនាគារកម្ពុជា បានបណ្តាលអោយមានបញ្ហាចង្អៀតណែនកាន់តែកើនខ្លាំងឡើងជាលំដាប់ ។ ក្នុងករណីមួយគឺចំនួនពិរុទ្ធនិងទណ្ឌិតមានកំណើនច្រើនរហូតដល់ទៅបីដងលើសចំនួនកំណត់ដែលអគារពន្ធនាគារអាចផ្ទុកបាន ដោយហេតុនេះ ពួកគេត្រូវរកវិធានការណ៍ដោះស្រាយបញ្ហាចង្អៀតណែននេះ ដោយចងព្យួររបស់របរដែលគេមានទាំងប៉ុន្មានទៅនឹងពិដានអគារ ដើម្បីបន្ថយបញ្ហាចង្អៀតណែននេះ ។ ប៉ុន្តែទោះបីជាមានការចាត់វិធានការណ៍ ដើម្បីដោះស្រាយភាពចង្អៀតនេះខ្លះៗ ដូចជា ផ្ទេរអ្នកទោសពីពន្ធនាគារដែលចង្អៀតណែនខ្លាំងទៅពន្ធនាគារដែលមិនសូវចង្អៀត ឬ កសាងបន្ទប់ឃុំ

ឃាំងបន្ថែមទៀតក៏ដោយក៏ស្ថានភាពរស់នៅចង្អៀតណែននេះ នៅតែជាសភាពការណ៍មួយយ៉ាប់យ៉ឺនដុនដាបដដែល ។

កង្វះថវិកាសំរាប់ពន្ធនាគារ គឺជាហេតុផលមួយដែលត្រូវតុលាការលើកឡើងថាជាមូលហេតុដែលបណ្តាលអោយមានការឃុំឃាំងលើសនីតិវិធី ហើយច្រើនតែឃុំលើស៦ខែ ដែលជារយៈពេលមួយកំណត់ដោយច្បាប់កម្ពុជា ។ ទោះបីជាការអនុវត្តន៍បែបនេះជាការខុសច្បាប់ក្តី ក៏គេនៅបានបន្តប្រព្រឹត្តខុសឆ្គងចំពោះសិទ្ធិរបស់អ្នកទោសក្នុងកិច្ចការពារតាមផ្លូវច្បាប់ទៀតផងដែរ ។ ករណីដែលចាត់ទុកថាត្រូវបានឃុំឃាំងលើសនីតិវិធីច្រើនលើសលប់នោះ គឺករណីរបស់ពួកកងទ័ពសេរីការជាតិកម្ពុជា (CFF) បានបង្ហាញនូវការកំរិតលទ្ធភាពនៃការចូលជួបរបស់មេធាវីព្រមទាំងការកាត់ក្តីមិនយុត្តិធម៌ ព្រោះអ្នកទោសក្រុមនេះមួយចំនួនត្រូវបានគេហាមមិនអោយជួបមេធាវីដើម្បីប្រឹក្សាបញ្ហារបស់គេ ។

អំពើទារុណកម្មនិងមរណៈភាពនៅក្នុងពន្ធនាគារក៏នៅតែជាបញ្ហាធ្ងន់ធ្ងរជាចំបងពីរ ដែលអ្នកទោសនៅក្នុងពន្ធនាគារកម្ពុជាកំពុងតែប្រឈមមុខនៅឡើយ ។ ក្នុងចំណោមទណ្ឌិតនិងពិរុទ្ធជនដែលយើងបានធ្វើការសិក្សាស្រាវជ្រាវកន្លងមក១១,៧%បានរាយការណ៍ថាត្រូវបាននរគបាលធ្វើទារុណកម្មមុននឹងត្រូវបានបញ្ជូនមកដល់ពន្ធនាគារ នឹង១,២%ក៏បានរាយការណ៍ថាបានទទួលរងទារុណកម្មខ្លះៗនៅក្នុងពន្ធនាគារដែរ ។ នៅក្នុងពន្ធនាគារមួយចំនួននៅមានការប្រើប្រាស់ខ្នោះឃ្នាបខុសច្បាប់នៅឡើយ ជាពិសេសនៅពន្ធនាគារក្រុងព្រះសីហនុនិងពន្ធនាគារខេត្តកំពង់ធំ ។ ចំណែកឯនៅពន្ធនាគារក្រុងព្រះសីហនុវិញ អ្នកទើបចូលមកដល់ថ្មីៗត្រូវទទួលរងការវាយបំបាក់ជំហរស្មារតីដោយឆ្មាំពន្ធនាគារនៅក្នុងពន្ធនាគារ ដែលជារូបភាពនៃពិធីស្វាគមន៍បញ្ចូលសមាជិកថ្មី ។ មរណៈភាពនៃទណ្ឌិត និង ពិរុទ្ធជនក្នុងពន្ធនាគារ (៥៣)នាក់ ភាគច្រើនគឺបណ្តាលមកពីជំងឺរួមទាំងជំងឺអេដស៍ផងដែរ ប៉ុន្តែក៏មាន៣នាក់ស្លាប់ដោយការធ្វើអត្តឃាតដែរ។

នៅក្នុងឆ្នាំ២០០១ នេះ ពិរុទ្ធជន និង ទណ្ឌិតទាំងឡាយមិនអាចមានលទ្ធភាពក្នុងការបន្ធូរបរិយាកាសវិញបានឡើយ ពីព្រោះបុគ្គលិកពន្ធនាគារបានខកខានដោយមិនបានអនុញ្ញាតអោយពិរុទ្ធជន និង ទណ្ឌិតទាំងនោះចាកចេញក្រៅពីបន្ទប់ឃុំឃាំងរបស់គេ ដើម្បីស្រូបយកខ្យល់អាកាសខាងក្រៅជាប្រចាំតាមពេលម៉ោងដូចដែលមានចែងនៅក្នុងនីតិវិធីពន្ធនាគារឡើយ ។ បញ្ហាដ៏ធំនេះត្រូវបាននាយកពន្ធនាគារភាគច្រើនបានលើកការត្អូញត្អែរពីការដាក់លើសចំណុះ ដែលមានពិរុទ្ធជននិងទណ្ឌិតច្រើនពេក ហើយពុំមានកំលាំងការពារគ្រប់គ្រាន់យកមកធ្វើជាមូលហេតុ ។ បញ្ហាដ៏អាក្រក់ហួសហេតុនេះបានកើតឡើងនៅពន្ធនាគារតាខ្មៅ ខេត្តកណ្តាលដែលអ្នកទោសចូលថ្មីមួយចំនួនត្រូវបានគេឃុំឃាំងទុកក្នុងបន្ទប់ឃុំឃាំងអស់រយៈពេលមួយខែ ដោយមិនដែលអោយពួកគេចេញក្រៅបានឃើញពន្លឺថ្ងៃបន្តិចទាល់តែសោះ ។ លើសពីនេះទៅទៀត ការស៊ីសំណូកក៏ជាបញ្ហាមួយដែលរារាំងមិនអោយពិរុទ្ធជន និង ទណ្ឌិតទាំងនោះបានទទួលការសាកសួរសុខទុក្ខពីសំណាក់ក្រុមគ្រួសារថែមទៀតផង ជាពិសេសករណីបែបនេះមានកើតឡើងនៅពន្ធនាគារមណ្ឌលកែប្រែទី១ ។ គ្រួសារដែលមកសួរសុខទុក្ខត្រូវ ចំណាយថវិកាជាច្រើនពាន់រៀល សំរាប់សូកឆ្មាំពន្ធនាគារដែលយាមតាមចំណុចត្រួតពិនិត្យមួយ

ចំនួនតាមច្រកចូលពន្ធនាគារ ដែលទង្វើនេះជាការរំលោភបំពានទៅនឹងនីតិវិធីពន្ធនាគារកម្ពុជា និង បទដ្ឋានអន្តរជាតិមួយចំនួន ។

## អនុសាសន៍

### បញ្ហាចង្អៀតណែន

១. រាជរដ្ឋាភិបាលកម្ពុជាត្រូវតែចាត់វិធានការណ៍ជាបន្ទាន់ និង ជាជំហាន១ ដើម្បីកាត់បន្ថយបញ្ហាចង្អៀតណែននៅក្នុងពន្ធនាគារកម្ពុជា ។ វិធានការណ៍នេះអាចរួមមាន ការសាងសង់អគារពន្ធនាគារថ្មី ឬ ជួសជុលកែលំអអគារពន្ធនាគារដែលមានស្រាប់ ដើម្បីអោយពិរុទ្ធជននិងទណ្ឌិតទាំងនោះមានកន្លែងស្នាក់នៅធំទូលាយជាងមុន ។

២. បើលើកយកការកើនឡើងយ៉ាងខ្ពស់ដោយមិនប្រែប្រួលនូវចំនួនទណ្ឌិត និង ពិរុទ្ធជនក្នុងកំឡុងពេលប្រាំឆ្នាំកន្លងទៅនេះ រាជរដ្ឋាភិបាលកម្ពុជាត្រូវតែរៀបចំផែនការ ដើម្បីទទួលយកទណ្ឌិត និង ពិរុទ្ធជនដែលនឹងត្រូវចូលមកថ្មី១ថែមទៀត ដែលមានលក្ខខណ្ឌរស់នៅសមរម្យជាជាងការបន្តដាក់ពួកគេទាំងនោះនៅក្នុងអគារដែលមានសភាពចង្អៀតណែនខ្លាំងស្រាប់ ។

### ការឃុំខ្លួនបណ្តោះអាសន្ន

៣. យោងតាមច្បាប់ពាក់ព័ន្ធទាំងឡាយ រាជរដ្ឋាភិបាលកម្ពុជាត្រូវតែចាត់វិធានការណ៍ចាំបាច់គ្រប់ជំហានទាំងអស់ ដើម្បីទប់ស្កាត់កុំអោយមានការឃុំខ្លួនបណ្តោះអាសន្នហួសនីតិវិធី នោះគឺការឃុំខ្លួនបណ្តោះអាសន្នទាំងឡាយណាដែលលើសនីតិវិធីកំណត់ ៦ខែ ។

៤. រាជរដ្ឋាភិបាលកម្ពុជា ត្រូវតែកំណត់អោយបានច្បាស់ថា តើអង្គភាពណាមួយដែលត្រូវទទួលបន្ទុកក្នុងការដឹកជញ្ជូនពិរុទ្ធជនទាំងឡាយពីពន្ធនាគារទៅ/មកតុលាការ គឺដើម្បីជៀសវាងការភាន់ច្រឡំតួនាទីនេះរវាងក្រសួងមហាផ្ទៃ និងស្ថាប័នតុលាការ ។

៥. រាជរដ្ឋាភិបាលកម្ពុជាត្រូវតែដោះស្រាយបញ្ហាពុករលួយដែលកំពុងតែមាននៅក្នុងការដឹកជញ្ជូនពិរុទ្ធជនទៅ/មកតុលាការនេះ ហើយត្រូវតែចាត់វិធានការលុបបំបាត់អំពើនេះអោយបានជាបន្ទាន់ ។

៦. រាជរដ្ឋាភិបាលកម្ពុជាគួរតែធានាអោយពិរុទ្ធជនគ្រប់រូបបានចូលរួមក្នុងសវនាការរបស់ពួកគេ ដោយមិនអាចខកខានបានដោយសារមូលហេតុណាមួយឡើយ រួមទាំងមូលហេតុខ្វះថវិកាសំរាប់សូកដើម្បីអោយមានមធ្យោបាយដឹកជញ្ជូនផងដែរ។ រាជរដ្ឋាភិបាលកម្ពុជាត្រូវតែទទួលស្គាល់ថា ពិរុទ្ធជនគ្រប់រូបមានសិទ្ធិក្នុងការចូលរួមស្តាប់ករណីរបស់គេនៅពេលជុំនំជំរះក្នុងអង្គសវនាការ ព្រមទាំងមានសិទ្ធិក្នុងការចូលរួមឆ្លើយតបក្នុងសវនាការនោះថែមទៀតផង ។

៧. រាជរដ្ឋាភិបាលកម្ពុជាត្រូវតែចាត់វិធានការគ្រប់ជំហាន ដើម្បីទប់ស្កាត់ការកើតឡើងសារជាថ្មីចំពោះការប្រព្រឹត្តមិនសមស្របមួយចំនួន ដូចជាការអនុវត្តន៍ចំពោះករណីរបស់ក្រុមកងទ័ពសេរីការជាតិកម្ពុជាដែលជាករណីមានការផ្តោតអារម្មណ៍ខ្លាំង ។ នៅពេលអនាគត ករណីពិរុទ្ធជនដែលគេផ្តោតអារម្មណ៍ខ្លាំង ឬទាក់ទិនក្នុងរឿងនយោបាយទាំងឡាយ មិនគួរត្រូវបានប្រព្រឹត្តខុសគ្នាពីពិរុទ្ធជនដទៃទៀតឡើយ ពួកគេគួរត្រូវបានអនុញ្ញាតអោយបុគ្គលិកសិទ្ធិមនុស្ស មេធាវីការពារក្តី និង សមាជិកគ្រួសារគេបានចូលជួបសាកសួរពត៌មាន/សុខទុក្ខផង ។

## អំពើទារុណកម្ម

៨. រាជរដ្ឋាភិបាលកម្ពុជាត្រូវតែអនុវត្តជាជំហានដើម្បីលុបបំបាត់ចោលការប្រើប្រាស់អំពើទារុណកម្មទាំងឡាយ ។

៩. វិធានការពិសេសមួយដែលត្រូវចាត់ការផងដែរនោះគឺតុលាការត្រូវតែផ្តន្ទាទោសបុគ្គលិកពន្ធនាគារ និងនគរបាលទាំងឡាយណាដែលត្រូវបានចោទប្រកាន់ពីបទល្មើសថាបានប្រព្រឹត្តិអំពើទារុណកម្ម ហើយក្នុងករណីបែបនេះរាជរដ្ឋាភិបាលកម្ពុជាគួរតែចាត់វិធានការចាំបាច់ទាំងឡាយដើម្បីសហការក្នុងការផ្តន្ទាទោសជនល្មើសបែបនេះ ។

## មរណៈភាពក្នុងពន្ធនាគារ

១០. យោងតាមច្បាប់កម្ពុជា ដែលបានចែងថា ត្រូវផ្តល់ការថែរក្សាសុខភាពអោយបានគ្រប់គ្រាន់សមរម្យដល់អ្នកទោសទាំងឡាយណាដែលរងទុក្ខវេទនាដោយជំងឺអេដស៍ និង ជំងឺណាដែលគំរាមកំហែងដល់អាយុជីវិត ។[១៧]

## ការបន្ធូរបរិយាកាស និងការសួរសុខទុក្ខរបស់សមាជិកគ្រួសារ

១១. រាជរដ្ឋាភិបាលត្រូវតែខិតខំជំរុញអោយនាយកពន្ធនាគារផ្តល់ការអនុញ្ញាតអោយទណ្ឌិតនិងពិរុទ្ធជនទាំងឡាយបានចេញពីបន្ទប់ឃុំឃាំងរបស់គេ ដើម្បីស្រូបយកខ្យល់អាកាសខាងក្រៅអោយបានមួយម៉ោងក្នុងមួយថ្ងៃជារៀងរាល់ថ្ងៃ ដូចដែលមានចែងក្នុងមាត្រាទី២១ នៃ *បទបញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រងចំពោះអ្នកទោស ។*

១២. រាជរដ្ឋាភិបាលកម្ពុជាគួរតែផ្តល់ថវិកាបន្ថែមមួយចំនួនទៀតដើម្បីបង្កើនចំនួនបុគ្គលិកពន្ធនាគារ ព្រមទាំងជំរុញអោយមានឆ្មាំពន្ធនាគារជាស្ត្រីភេទផងដែរ ដើម្បីធានាអោយមានកំលាំងការពារគ្រប់គ្រាន់ និង ដើម្បីអោយពិរុទ្ធជននិងទណ្ឌិតទាំងឡាយបានចេញពីបន្ទប់ឃុំឃាំងរបស់ពួកគេដើម្បីហាត់ប្រាណ

---

[17] *សូមអាន "សិទ្ធិមនុស្សនិងពន្ធនាគារកម្ពុជា -របាយការណ៍សុខភាពលីកាដូ ឆ្នាំ ២០០១ ដើម្បីជ្រាបពត៌មានបន្ថែមនិង អនុសាសន៍ ។*

ស្រូបយកខ្យល់អាកាសខាងក្រៅ និងត្រូវពន្លឺថ្ងៃដែលជាកត្តាដ៏សំខាន់មួយជួយការពារទប់ស្កាត់ជំងឺក្នុងចំណោមអ្នកទោសទាំងនោះ ។

១៣. រាជរដ្ឋាភិបាលកម្ពុជាក៏ត្រូវចាត់វិធានការជាបន្ទាន់មួយទៀតដែរ ដើម្បីលុបបំបាត់នូវអំពើសូកប៉ាន់ប្រាក់ទាំងឡាយដែលកើតមានក្នុងពន្ធនាគារក្នុងខណៈពេលដែលមានសមាជិកគ្រួសារចូលសួរសុខទុក្ខពិរុទ្ធជន និង ទណ្ឌិត ។

## ឯកសារពិគ្រោះ

### របាយការណ៍អង្គការលីកាដូ

- លីកាដូ ១៩៩៧ "ពន្ធនាគារកម្ពុជា-បញ្ហាសិទ្ធិមនុស្សមួយចំនួន" ខែឧសភា
- លីកាដូ ១៩៩៨ "ពន្ធនាគារកម្ពុជា-បញ្ហាសិទ្ធិមនុស្សមួយចំនួន" ខែមករា
- លីកាដូ ១៩៩៩ "ពន្ធនាគារកម្ពុជា-បញ្ហាសិទ្ធិមនុស្សមួយចំនួន" ខែកញ្ញា
- លីកាដូ ២០០០ "ពន្ធនាគារកម្ពុជា ១៩៩៩ : ស្ថានភាព និង ការរំលោភសិទ្ធិមនុស្ស" ខែកក្កដា
- លីកាដូ ២០០១ "សិទ្ធិមនុស្ស និង ពន្ធនាគារកម្ពុជា : របាយការណ៍សុខភាពលីកាដូ ២០០១"

### ច្បាប់ជាតិ

"នីតិវិធីពន្ធនាគារ" ១៩៩៨ រៀបរៀងដោយនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី៥ ខែឧសភា ។

បញ្ញត្តិដែលពាក់ព័ន្ធទៅនឹងតុលាការ និង ច្បាប់ព្រមទាំងនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៥ ដែលអនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល *កម្រងឯកសារច្បាប់សង្ខេបកម្ពុជា* បោះពុម្ពលើកទី១ ដោយរាជរដ្ឋាភិបាលកម្ពុជានៅរាជធានីភ្នំពេញ ។

### ឯកសារច្បាប់សិទ្ធិមនុស្សអន្តរជាតិ

១. បទបញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រងចំពោះអ្នកទោស:

អនុម័តដោយមហាសន្និបាតលើកទី១របស់អង្គការសហប្រជាជាតិ ស្តីពីការទប់ស្កាត់បទឧក្រិដ្ឋ និង ការប្រព្រឹត្តិចំពោះជនល្មើសដែលប្រារព្ធឡើងនៅទីក្រុងហ្សឺណែវ ឆ្នាំ១៩៥៥ ហើយដែលត្រូវបានក្រុមប្រឹក្សា សេដ្ឋកិច្ច និង សង្គម ឯកភាពយល់ស្របតាមសេចក្តីសំរេចលេខ៦៦៣ C (XXIV) ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៥៧ និង សេចក្តីសំរេចលេខ២០៧៦ (LXII) ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៧៧ ។

ចំពោះអត្ថបទ ពេញលេញ សូមរកតាមអាសយដ្ឋាន
http://www.unhchr.ch/html/menu3/b/h_comp35.htm

២. គោលការណ៍គ្រឹះសំរាប់អនុវត្តចំពោះអ្នកទោស :

អនុម័ត និង ប្រកាសដោយសេចក្តីសំរេចនៃមហាសន្និបាត លេខ៤៥ /១១១ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩០ ។

ចំពោះអត្ថបទពេញលេញ សូមរកតាមអាសយដ្ឋាន
http://www.unhchr.ch/html/menu3/b/h_comp34.htm

# សេចក្តីកែតំរូវ

| ទំព័រ | បន្ទាត់ | អត្ថន័យចាស់ | អត្ថន័យកែតំរូវ |
|---|---|---|---|
| ៤ | ១៣ | នីតិវិធីពន្ធនាគារកម្ពុជា ប្រការ ៣៤.១ ជំពូក ៤ | នីតិវិធីពន្ធនាគារកម្ពុជា លេខ ៣៤ ចំណុច ៤ |
| ៥ | ២១ | ទីកន្លែងង្សៀត | ទីកន្លែងចង្អៀត |
| ៧ | ៦ | មូលនិធិដែលបានផ្តល់មកពីម្ចាស់មូលនិធិអូស្ត្រាលី សំរាប់កសាងពន្ធនាគារថ្មីនៅកំពង់ធំ | មូលនិធិដែលបានផ្តល់មកពីម្ចាស់មូលនិធិអូស្ត្រាលី បានកសាងអគារថ្មីនៅក្នុងពន្ធនាគារកំពង់ធំ |
| ៩ | ៥ | នីតិវិធីពន្ធនាគារកម្ពុជា ប្រការ ៣៤.១ ជំពូក ៤ | នីតិវិធីពន្ធនាគារកម្ពុជា លេខ ៣៤ ចំណុច ៤ |
| ១០ | ១១ | នីតិវិធីពន្ធនាគារកម្ពុជា ប្រការ ៣៤.១ ជំពូក ៥ | នីតិវិធីពន្ធនាគារកម្ពុជា លេខ ៣៤ ចំណុច ៥ |
| ១៩ | ១៦ | នៅក្នុងនីតិវិធីពន្ធនាគារ មាត្រាទី ៨.២ ជំពូក ៤ | នៅក្នុងនីតិវិធីពន្ធនាគារកម្ពុជា លេខ ៨ ចំណុច ៤ |
| ២០ | ៤ | លើសពីនេះទៅទៀត មាត្រាទី ៨.៦ ជំពូក ១៨ | លើសពីនេះទៅទៀត នីតិវិធីពន្ធនាគារកម្ពុជា លេខ ៨ ចំណុច ១៨ |
| ២១ | ១៥ | មណ្ឌលក្រែប្រែ ម១ ម២ ម៣ ម៥ | មណ្ឌលកែប្រែ ម១ ម២ ម៣ |